មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែមិថុនា ឆ្នាំ២០១៦

# ការវិភាគផ្លូវច្បាប់

## ជុំវិញការចោទប្រកាន់ទៅលើសកម្មជនអង្គការមាតាធម្មជាតិបួនរូប

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ជាអង្គការមិនមែនរដ្ឋាភិបាល មិនមាននិន្នាការនយោបាយ ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

ប្រសិនបើលោក អ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ម.ស.ម.ក តាមរយៈ អាសយដ្ឋាន ផ្ទះលេខ ៧៩៨ ផ្លូវលេខ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

អ៊ីម៉ែល ៖ info@cchrcambodia.org
ទូរសព្ទ ៖ +៨៥៥ (0) ២៣ ៧២៦ ៩០១
ទូរសារ ៖ +៨៥៥ (0) ២៣ ៧២៦ ៩០២
គេហទំព័រ ៖ www.cchrcambodia.org

# មាតិកា


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ..... i
១ សេចក្ដីផ្ដើមនិងមូលន័យសង្ខេប ..... 1
២ បរិបទ ..... 2
អង្គការមាតាធម្មជាតិ ..... 2
ការបូមខ្សាច់ក្នុងខេត្តកោះកុង ..... 3
ជនត្រូវចោទ ៖ សាន់ ម៉ាឡា ទ្រី សុវិកា ស៊ីម សំណាង និង អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន ..... 7
៣ សាវតារនៃអង្គហេតុ ..... 7
ស៊ីម សំណាង ទ្រី សុវិកា និង សាន់ ម៉ាឡា ..... 7
អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន ..... 9
៤ អង្គច្បាប់ ..... 10
បទល្មើសនៃការគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ ..... 10
ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងនាមជាអ្នកសមគំនិតក្នុងបទល្មើស ..... 11
ស្តង់ដារនៃភស្តុតាងចំពោះបទល្មើសព្រហ្មទណ្ឌ ..... 11
ការដាក់បន្ទុកចំពោះបទល្មើសព្រហ្មទណ្ឌ ..... 12
សិទ្ធិទទួលបានសេរីភាព និងសិទ្ធិមិនត្រូវបានគេឃុំខ្លួនតាមអំពើចិត្ត ..... 12
សវនាការកំបាំងមុខ ..... 15
សេរីភាពខាងការបញ្ចេញមតិ និងការប្រមូលផ្តុំ ..... 16
៥ ការវិភាគជុំវិញការយកច្បាប់មកអនុវត្តចំពោះអង្គហេតុ ..... 16
បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ (ព្រហ្មទណ្ឌក្រមនៃ ៤២៤មាត្រា ) ..... 16
ភាពមិនស៊ីសង្វាក់ និងភាពខ្សោយនៃភស្តុតាងដែលមាន ..... 17
កង្វះខាតភស្តុតាងជាក់លាក់ដែលថាជនត្រូវចោទបានគំរាមកំហែងថានឹងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ..... 18
ភស្តុតាងដោះបន្ទុកដែលបញ្ជាក់ថាសកម្មភាពរបស់ជនជាប់ឃុំពិតជាអហិង្សា ហើយពួកគេព្យាយាមធ្វើឱ្យស្ថានការណ៍ស្ងប់ស្ងាត់ ..... 20
ការទទួលខុសត្រូវរបស់អ្នកសមគំនិត (ព្រហ្មទណ្ឌក្រមនៃ ២៩មាត្រា ) ..... 21
ការទទួលខុសត្រូវរបស់អ្នកសមគំនិតត្រូវតែផ្អែកលើសកម្មភាពជាក់ស្តែង ..... 22
អ្នកសមគំនិតត្រូវមានចេតនាក្នុងការសម្របសម្រួលឱ្យមានបទល្មើស ..... 23
ត្រូវតែជាបទល្មើសព្រហ្មទណ្ឌជាក់ស្តែង ..... 23
៦ បញ្ហាច្បាប់ដែលពាក់ព័ន្ធ ..... 24

ការឃុំខ្លួនបណ្តោះអាសន្នរយៈពេលយូរ ........ 24
៧ សេចក្តីសន្និដ្ឋាន ........ 27
ឧបសម្ព័ន្ធទី ១ ៖ ការឆ្លើយឆ្លងតាមទំព័រហ្វេសប៊ុក (លើអេក្រង់រូបភាព) ........ 30
ឧបសម្ព័ន្ធទី ២ ៖ វីដេអូដែលថតដោយ សាន់ ម៉ាឡា នៅថ្ងៃទី១២ ខែសីហា ........ 32
ឧបសម្ព័ន្ធទី៣ ៖ វីដេអូជាសារសំឡេងពី ទ្រី សុរិគា នៅថ្ងៃទី១២ ខែសីហា ........ 33

# ការវិភាគជុំវិញការចោទប្រកាន់ទៅលើសកម្មជនអង្គការមាតាធម្មជាតិបួនរូប

## ១ សេចក្តីផ្តើមនិងមូលន័យសង្ខេប

១. នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ លោក សាន់ ម៉ាឡា លោក ទ្រី សុវិកា និង លោក ស៊ឹម សំណាង (ជនត្រូវចោទដែលកំពុងជាប់ឃុំ) ត្រូវបានចាប់ខ្លួននិងចោទប្រកាន់តាមមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ពីបទគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ។ អ្នកទាំងនោះត្រូវបានឃុំខ្លួនក្នុងពន្ធនាគារខេត្តកោះកុងចាប់តាំងពីពេលចាប់ខ្លួនមកម្ល៉េះ។ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ មានការលេចឮជាសាធារណៈថាលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន ត្រូវបានចោទប្រកាន់ក្រោមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌថាជាអ្នកសមគំនិតក្នុងបទល្មើសដូចគ្នា។ នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១៦ តុលាការខេត្តកោះកុងបានសម្រេចបំបែករឿងក្តីនេះចេញជាពីរផ្នែក ដោយ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុននឹងត្រូវជំនុំជម្រះផ្សេងពីជនត្រូវចោទទាំងបីអ្នកនោះ ។ កាលបរិច្ឆេទនៃការជំនុំជម្រះចំពោះជនត្រូវចោទទាំងបីនឹងត្រូវធ្វើឡើងនៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៦ នៅសាលាដំបូងខេត្តកោះកុង។ ប៉ុន្តែមកដល់មកនេះ កាលបរិច្ឆេទការជំនុំជម្រះចំពោះ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន មិនទាន់ត្រូវបានកំណត់នៅឡើយទេ។

២. នៅមុនការជំនុំជម្រះ ការវិភាគផ្លូវច្បាប់នេះមានគោលបំណងពិនិត្យមើលថាតើការចោទប្រកាន់ទៅលើជនត្រូវចោទទាំងបួននាក់នោះ ព្រមទាំងរយៈពេលយូរនៃការឃុំខ្លួនបណ្តោះអាសន្នទៅលើអ្នកដែលជាប់ឃុំទាំងបីនាក់នោះមានហេតុផលសមរម្យ និងមានភស្តុតាងគាំទ្រគ្រប់គ្រាន់ដែរឬយ៉ាងណា។ ការវិភាគផ្លូវច្បាប់នេះមានគោលបំណង (១) លើកឡើងពីបរិបទនិងសាវតារជាក់ស្តែងនៅក្នុងករណីនេះ (២) បង្ហាញពីសាវតារនៃអង្គហេតុ និងការចោទប្រកាន់ទៅលើជនត្រូវចោទទាំងបួននាក់ ការឃុំខ្លួនទៅលើជនត្រូវចោទទាំងបីនាក់ និងការនីរទេសខ្លួនលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន ដោយបង្ខំពីប្រទេសកម្ពុជា (៣)លើកឡើងពីទិដ្ឋភាពទូទៅជុំវិញការអនុវត្តច្បាប់ជាតិ និងកាតព្វកិច្ចចំពោះបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ (៤) វិភាគទៅលើការចោទប្រកាន់ និងការលើកយកច្បាប់មកអនុវត្តចំពោះអង្គហេតុដែលកើតឡើង (៥) ពិនិត្យមើលទៅលើបញ្ហាផ្លូវច្បាប់ដែលពាក់ព័ន្ធក្នុងនោះរួមទាំងសិទ្ធិមានវត្តមានក្នុងពេលជំនុំជម្រះរបស់លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន និងនិត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្នរយៈពេលយូរទៅលើអ្នកជាប់ឃុំបីនាក់នោះនិង (៦) ធ្វើសេចក្តីសន្និដ្ឋានជុំវិញការឃុំខ្លួនបណ្តោះអាសន្នរយៈពេលយូរទៅលើសកម្មជនទាំងបីនាក់គឺធ្វើឡើងតាមតែអំពើចិត្ត ព្រោះថាការសមគំនិតក្នុងបទល្មើសនោះមិនសមនឹងទាក់ទងជាមួយនឹងលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន ឡើយហើយការចោទប្រកាន់ទៅលើជនត្រូវចោទទាំងបីនាក់នោះគ្មានមូលដ្ឋានច្បាស់លាស់ ដោយសារកង្វះភស្តុតាងដាក់បន្ទុកទៅលើអ្នកទាំងនោះ។

៣. អង្គហេតុមានលើកឡើងក្នុងអត្ថបទវិភាគផ្លូវច្បាប់នេះត្រូវបាន ម.ស.ម.ក ប្រមូលមកពីប្រភពផ្សេងៗ ព្រមទាំងការសម្ភាសជាមួយលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន (ដែលបានបញ្ជូនព័ត៌មានមកកាន់ ម.ស.ម.ក) ការសួរសុខទុក្ខសកម្មជនដែលកំពុងជាប់ឃុំទាំងនោះនៅពន្ធនាគារ ការសម្ភាសជាមួយសាក្សីមួយចំនួនដែលមានវត្តមាននៅក្នុងការតវ៉ាទាំងនោះ និងការតាមដានព័ត៌មាននៅលើបណ្តាញផ្សព្វផ្សាយព័ត៌មាននានា។ ឈ្មោះរបស់សាក្សីទាំងនោះមិនត្រូវបានលាតត្រដាងឡើយ ដើម្បីការពារឯកជនភាព និងសន្តិសុខរបស់ពួកគេ។

## ២ បរិបទ

*អង្គការមាតាធម្មជាតិ*

៤. អង្គការមាតាធម្មជាតិជាអង្គការដែលមានទំនាក់ទំនងជាមួយនឹងជនត្រូវចោទទាំងបួននោះ។ អង្គការនេះគឺជាអង្គការថ្នាក់មូលដ្ឋានមួយដែលបានបង្កើតឡើងក្នុងឆ្នាំ២០១២ ដើម្បីធ្វើយុទ្ធនាការប្រឆាំងទៅនឹងការបំផ្លាញធនធានធម្មជាតិរបស់ប្រទេសកម្ពុជា ជាពិសេសនៅក្នុងខេត្តកោះកុង។ អង្គការនេះដឹកនាំដោយសហគមន៍ ហើយភាគច្រើនមានការចូលរួមពីសកម្មជនផ្នែកបរិស្ថាន និងសកម្មជនសិទ្ធិមនុស្សកម្ពុជាដែលរួបរួមគ្នាដើម្បីការពារសម្រស់ធម្មជាតិរបស់កម្ពុជា ធានាដល់ការប្រើប្រាស់ធនធានធម្មជាតិរបស់កម្ពុជាឱ្យមាននិរន្តរភាព និងការពាររបបចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ នៅគ្រប់ដំណាក់កាលនៃសកម្មនិយមរបស់អង្គការមាតាធម្មជាតិ មានបញ្ជាក់យ៉ាងច្បាស់នូវគោលការណ៍មួយចំនួននៅលើគេហទំព័ររបស់អង្គការ[1] ដែលថារាល់សកម្មភាពគ្រប់យ៉ាងត្រូវតែធ្វើឡើងដោយ"*សន្តិវិធី*"។ សកម្មជនទាំងអស់ត្រូវបានណែនាំយ៉ាងច្បាស់លាស់ដើម្បីធានាថាបាតុកម្មទាំងអស់ធ្វើឡើងដោយសន្តិវិធីទាំងស្រុង និងបញ្ឈប់សកម្មភាពភ្លាមប្រសិនបើព្រឹត្តិការណ៍នោះក្លាយទៅជាហិង្សា។ ជាញឹកញាប់ក្រុមសកម្មជនទាំងនេះបានបង្ហោះសារនៅលើបណ្តាញផ្សព្វផ្សាយសង្គមថាអង្គការមាតាធម្មជាតិធ្វើសកម្មភាពដោយសារតែក្តីស្រឡាញ់យ៉ាងជ្រាលជ្រៅលើបរិស្ថាន និងធនធានធម្មជាតិរបស់កម្ពុជា។

៥. យុទ្ធនាការលើកដំបូងរបស់អង្គការមាតាធម្មជាតិបានចាប់ផ្តើមនៅខែវិច្ឆិកា ឆ្នាំ២០១២ និងបានផ្តោតសំខាន់ទៅលើការជំទាស់នឹងផែនការសាងសង់ទំនប់វារីអគ្គិសនីនៅជ្រលងអារ៉ែងក្នុងខេត្តកោះកុង ដែលនឹងធ្វើឱ្យហិនហោចបរិស្ថាននៅក្នុងតំបន់នោះ និងបន្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋជនជាតិភាគតិច ជង មួយពាន់ប្រាំរយគ្រួសារចេញពីដីធ្លីដូនតារបស់ពួកគាត់។ យុទ្ធនាការនោះបានបង្អាក់ផែនការសាងសង់យ៉ាងហោចណាស់រហូតដល់ឆ្នាំ២០១៨ ខណៈដែលរាជរដ្ឋាភិបាលកម្ពុជា("រដ្ឋាភិបាល") ព្រមទទួលស្គាល់ថា ផែនការសាងសង់នេះនឹងនាំឱ្យមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានធម្មជាតិ ដោយថ្លែងថា *"រាជរដ្ឋាភិបាលនឹងមិនសាងសង់ទំនប់វារីអគ្គិសនីក្នុងតំបន់អារ៉ែងនោះទេ ប្រសិនបើការ*

[1] គេហទំព័ររបស់អង្គការមាតាធម្មជាតិ ។ អាចរកបានតាមរយៈ៖ <http://mothernature.pm/about-us.html>

*សិក្សាបង្ហាញថាមានការបាត់បង់ផលប្រយោជន៍ច្រើនលើសលប់ដោយសារការអភិវឌ្ឍ ប្រៀបធៀបនឹងសេដ្ឋកិច្ច និងអត្ថប្រយោជន៍ផ្សេងទៀត*"[2]។ យុទ្ធនាការនោះរួមមាន ការធ្វើសកម្មភាពផ្ទាល់ដោយសន្តិវិធីជាបន្តបន្ទាប់ និងការតស៊ូមតិជាសាធារណៈ ដែលទទួលបានការចាប់អារម្មណ៍ជាខ្លាំង និងទទួលបានការគាំទ្រនៅទូទាំងប្រទេសកម្ពុជា។ កន្លងមក គេមិនដែលឃើញមានការចោទប្រកាន់ពាក់ព័ន្ធក្នុងករណីនេះ ឬយុទ្ធនាការនានាផ្សេងទៀតរបស់អង្គការមាតាធម្មជាតិ ដែលថាអង្គការមាតាធម្មជាតិឬបុគ្គលជាប់ចោទក្នុងករណីនេះបានញុះញង់ឱ្យមានការតវ៉ាដោយហិង្សា ឬប្រព្រឹត្តបទល្មើសស្រដៀងគ្នានេះទេ។

### *ការបូមខ្សាច់ក្នុងខេត្តកោះកុង*

៦. យុទ្ធនាការជំទាស់ទៅនឹងការបូមខ្សាច់ក្នុងខេត្តកោះកុង ដែលទាក់ទងនឹងការចោទប្រកាន់នេះបានចាប់ផ្តើមនៅម្តុំកោះស្រឡៅ នៅខែមេសា ឆ្នាំ២០១៥ និងបានរាលដាលទៅដល់ស្រុកអណ្តូងទឹកនៅចុងខែកក្កដា ឆ្នាំ២០១៥ ជាទីកើតមានឧប្បត្តិហេតុដែលឈានដល់មានការចោទប្រកាន់នេះ។ ការធ្វើអាជីវកម្មបូមខ្សាច់នៅតាមស្ទឹងក្នុងខេត្តកោះកុងដើម្បីនាំចេញ ជាពិសេសសម្រាប់ការសាងសង់ និងសម្រាប់ប្រយោជន៍ផ្សេងៗ (ដូចជាចាក់ដីបំពេញបឹង សមុទ្រ) ភាគច្រើនទៅកាន់ប្រទេសសិង្ហបុរី[3] ដែលបានចាប់ផ្តើមតាំងពីដើមឆ្នាំ២០០៨។ ករណីនេះបានបន្តកើតមានតាំងពីពេលនោះមក។

៧. ក្របខ័ណ្ឌច្បាប់ដើម្បីគ្រប់គ្រងការបូមខ្សាច់បង្កើតឡើងដើម្បីធានាឲ្យមានការគោរពដល់សិទ្ធិរបស់សហគមន៍ដែលរងផលប៉ះពាល់ នៅពេលណាដែលមានការផ្តល់អាជ្ញាប័ណ្ណបូមខ្សាច់។ ខណៈដែលមាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[4] ចែងថារដ្ឋមានទំនួលខុសត្រូវចំពោះការការពារបរិស្ថានក្នុងការអនុវត្តន៍ជាក់ស្តែងគឺច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ("ច្បាប់បរិស្ថាន")[5] បានចែងពីកិច្ចការពារជាក់លាក់ចំពោះបរិស្ថាន និងធនធានធម្មជាតិរបស់កម្ពុជា។ មាត្រា ៨ នៃច្បាប់បរិស្ថានចែងយ៉ាងច្បាស់ថា ធនធានធម្មជាតិដែលរួមមានទាំងខ្សាច់ផងនោះត្រូវតែអភិរក្សនិងគ្រប់គ្រង ហើយត្រូវប្រើប្រាស់ "*ដោយសមហេតុផល ប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ*"[6]។ ជំពូក៣ នៃច្បាប់បរិស្ថានស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថានចែងថាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តចំពោះ "*រាល់គម្រោង និងសកម្មភាពឯកជនឬសាធារណៈ*" និងចំពោះ "*សកម្ម*

---

[2] ហ្សូមបើ ភីតធើ (Zsombor Peter)និង ឃួន ណារីម "លោកហ៊ុន សែន ការពារគម្រោងសាងសង់ទំនប់វារីអគ្គិសនី" សារព័ត៌មាន *ខេមបូឌា ដេលី* ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ។ អាចរកបានតាមរយៈ http://bit.ly/1tdt7ml

[3] អង្គការឃ្លាំមើលពិភពលោក (គ្លូបិលវីដណេស) "ការផ្ទេរខ្សាច់ ៖ តើតម្រូវការរបស់សិង្ហបុរីចំពោះខ្សាច់របស់ប្រទេសកម្ពុជា គំរាមកំហែងដល់ប្រព័ន្ធអេកូឡូហ្ស៊ី និងធ្វើឱ្យអន្តរាយដល់អភិបាលកិច្ចល្អយ៉ាងដូចម្តេច?" (ខែឧសភា ឆ្នាំ២០១០)។ អាចរកបានតាមរយៈ ៖ http://bit.ly/1QGodSC លីនហ្វាយ មើឌុច "សង្គ្រាមខ្សាច់៖ កំណើនសេដ្ឋកិច្ចរបស់សឹង្ហបុរីកើតឡើង តែប៉ះពាល់បរិស្ថានរបស់ប្រទេសជិតខាង" សារព័ត៌មាន ស៊ីដនី ម៉នីង ហ៊ែល (ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦)។ អាចរកបានតាមរយៈ ៖ http://bit.ly/1oPAiPT

[4] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣) មាត្រា ៥៩។

[5] ច្បាប់បរិស្ថាន (១៩៩៦)។

[6] ដូចខាងលើ មាត្រា ៨។

*ភាពដែលមានស្រាប់និងកំពុងដំណើរការ ហើយដែលពុំទាន់បានវាយតម្លៃផលប៉ះពាល់បរិស្ថាននៅឡើយ*[7]។ នីតិវិធីសម្រាប់ធ្វើការវាយតម្លៃពីផលប៉ះពាល់បរិស្ថានមានចែងក្នុងជំពូក ៣ នៃច្បាប់បរិស្ថាន អនុក្រឹត្យលេខ ៧២ ស្តីពីការវាយតម្លៃផលប៉ះពាល់បរិស្ថាន "អនុក្រឹត្យលេខ ៧២" និងបទបញ្ញាដែលពាក់ព័ន្ធមួយចំនួន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគួរត្រូវបានត្រួតពិនិត្យនិងវាយតម្លៃដោយក្រសួងបរិស្ថានមុននឹងបញ្ជូនទៅរដ្ឋាភិបាលដើម្បីសម្រេច[8]។ ម្យ៉ាងវិញទៀត អនុក្រឹត្យលេខ ៧២ តម្រូវឱ្យធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងទាំងអស់ពាក់ព័ន្ធក្នុងសកម្មភាពដូចមានបញ្ជាក់ក្នុងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយដែលរាប់បញ្ចូលទាំងការរុករករ៉ែ[9] បើទោះបីជាអនុក្រឹត្យនោះបានដាក់បញ្ចូលករណីលើកលែងសម្រាប់គម្រោងនានា ដែលត្រូវបានចាត់ទុកថាជា *"ករណីពិសេស... យល់ព្រមពីរដ្ឋាភិបាល"*[10]។ ខណៈដែលការចូលរួមជាសាធារណៈត្រូវបាន *"លើកទឹកចិត្ត"* តាមរយៈច្បាប់ស្តីពីការគ្រប់គ្រងនីតិវិធីវាយតម្លៃផលប៉ះពាល់បរិស្ថាន ក៏ពុំមានលក្ខខណ្ឌច្បាស់លាស់ណាមួយឡើយបានចែងនៅក្នុងច្បាប់នោះដែរ។ ជាងនេះទៅទៀត មិនមានចែងពីលក្ខខណ្ឌសម្រាប់ការចេញផ្សាយព័ត៌មានឡើយ។[11]

៨. នៅក្នុងខែឧសភា ឆ្នាំ២០០៩ នាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសហាមប្រាមលើការនាំខ្សាច់ចេញ រហូតដល់មានការសិក្សាពីបរិស្ថាន ដែលលោកបានអះអាងជាថ្មីនៅក្នុងខែកក្កដាឆ្នាំដដែលនោះផងដែរ[12]។ បើទោះជាមានបម្រាមក្តី មួយឆ្នាំក្រោយមករបាយការណ៍ចេញផ្សាយរបស់អង្គការក្លូបិលវីដណេស (Global Witness) ជាអង្គការផ្នែកបរិស្ថាននិងសិទ្ធិមនុស្សអន្តរជាតិដ៏លេចធ្លោ បានបង្ហាញថាបម្រាមនោះមិនត្រឹមតែមិនត្រូវបានគេគោរពតាមប៉ុណ្ណោះទេ ប៉ុន្តែការនាំខ្សាច់ចេញពីដែនសមុទ្រកម្ពុជារឹតតែកើនខ្លាំងឡើងថែមទៀត[13]។

៩. ផលប៉ះពាល់នៃការបូមខ្សាច់ទៅលើបរិស្ថានធម្មជាតិ និងលើរបរចិញ្ចឹមជីវិតរបស់សហគមន៍ក្នុងតំបន់ត្រូវបានអង្គការក្លូបិលវីដណេសស៊ើបអង្កេតក្នុងទ្រង់ទ្រាយធំ ដែលបានចេញផ្សាយរបាយការណ៍រិះគន់

---

[7] ដូចខាងលើ មាត្រា ៦។

[8] ដូចខាងលើ មាត្រា ៦ និងមាត្រា ៧។

[9] អនុក្រឹត្យស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន លេខ៧២ អនក្រ បក (ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩) ឧបសម្ព័ន្ធទី ៦ ។ អាចរកបានតាមរយៈ៖ http://bit.ly/1W6ovu4។

[10] ដូចខាងលើមាត្រា ២។

[11] អង្គការផេក "កំណត់ត្រាស្តីពីការវាយតម្លៃហេតុប៉ះពាល់ទន្លេមេគង្គ ៖ ការវិភាគប្រៀបធៀបលើការវាយតម្លៃលើហេតុប៉ះពាល់បរិស្ថាន (២០១៥)។ អាចរកបានតាមរយៈ ៖ http://bit.ly/25bSrab

[12] វង្ស សុខេង "លោក ហ៊ុន សែន ស្នើឱ្យមានបម្រាមលើការនាំខ្សាច់ចេញ ការសិក្សាពីផលប៉ះពាល់" សារព័ត៌មាន*ភ្នំពេញប៉ុស្តិ៍* (ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០០៩)។ អាចរកបានតាមរយៈ៖ http://bit.ly/1T0TUKu

[13] អង្គការក្លូបិលវីដណេស "ការផ្ទេរខ្សាច់ ៖ តើតម្រូវការរបស់សិង្ហបុរីចំពោះខ្សាច់របស់ប្រទេសកម្ពុជា គំរាមកំហែងដល់ប្រព័ន្ធអេកូឡូហ្ស៊ី និងធ្វើឱ្យអន្តរាយដល់អភិបាលកិច្ចល្អយ៉ាងដូចម្តេច?" (ខែឧសភា ឆ្នាំ២០១០)។ អាចរកបានតាមរយៈ ៖http://bit.ly/1QGodSC

ខ្លាំងៗចំនួនពីរក្នុងឆ្នាំ២០០៩[14] និង២០១០។[15] សហជីពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) ដែលជាបណ្ដាញនៃអ្នកវិទ្យាសាស្ត្រធ្វើការផ្នែកបរិស្ថានពិភពលោកជាយូរឆ្នាំមកហើយ អង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីរដ្ឋាភិបាល ដែលមានកិច្ចសហការជាមួយរដ្ឋាភិបាលកម្ពុជា តាមរយៈកម្មវិធីអភិរក្សបរិស្ថាន[16] បានរាយការណ៍ផងដែរអំពីផលប៉ះពាល់ពីការបូមខ្សាច់នោះ[17]។ អ្នកជំនាញទាំងនោះបានរាយការណ៍ពីការស៊ើបអង្កេតផ្ទាល់របស់អង្គការមោតាធម្មជាតិ និងបទពិសោធន៍ផ្ទាល់របស់សហគមន៍មូលដ្ឋានទាំងអស់ដែលបង្ហាញពីផលប៉ះពាល់ធំធេងបង្កឡើងដោយសារការបូមខ្សាច់នៅក្នុងតំបន់នេះ។ ផលប៉ះពាល់មួយចំនួនក្នុងចំណោមផលប៉ះពាល់ធំៗបំផុតនោះគឺការកាត់បន្ថយបរិមាណត្រីដែលធ្វើឱ្យប៉ះពាល់ទាំងបរិស្ថានធម្មជាតិ និងរបរចិញ្ចឹមជីវិតរបស់សហគមន៍ក្នុងតំបន់។ ជាមួយគ្នានេះផងដែរ សាឡង់បូមខ្សាច់ត្រូវបានគេរាយការណ៍ថា តែងតែបង្កឱ្យខូចខាតដល់ឧបករណ៍នេសាទរបស់សហគមន៍មូលដ្ឋាន ថែមទាំងធ្វើឱ្យប៉ះពាល់ដល់របរចិញ្ចឹមជីវិតរបស់ពួកគេ។ ម្យ៉ាងទៀត ការបូមខ្សាច់ក៏ត្រូវបានគេភ្ជាប់ទៅនឹងការបាត់បង់ដីបណ្ដាលមកពីការរំលើងដើមកោងកាង និងផលប៉ះពាល់ពីការហូរច្រោះដីខ្លាំង។ លទ្ធផលស្រាវជ្រាវរបស់អង្គការ សហជីពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) បង្ហាញថាការនេសាទត្រូវបានកាត់បន្ថយយ៉ាងច្រើនរហូតដល់ ៧០ ទៅ ៩០ ភាគរយ។ ជាមួយគ្នានេះ ការទទួលរងផលប៉ះពាល់ដ៏ទូលំទូលាយទាំងនេះ សហគមន៍នៅក្នុងមូលដ្ឋានមិនទទួលបានផលប្រយោជន៍សេដ្ឋកិច្ចណាមួយពីការបូមខ្សាច់ឡើយ ព្រោះការងារទាំងនេះត្រូវបានគេផ្ដល់ទៅឱ្យជនចំណាកស្រុកមកពីតំបន់ផ្សេងៗនៃប្រទេសកម្ពុជា ឬមកពីក្រៅប្រទេស ហើយប្រាក់ចំណេញពីអាជីវកម្មនេះត្រូវបានក្រុមហ៊ុនសាជីវកម្មធំៗមួយចំនួនតូចប្រមូលយក។ ទីបី ការនាំយកចេញនូវបរិមាណខ្សាច់ដ៏ច្រើនសន្ធឹកសន្ធាប់ពីតាមដងស្ទឹងខេត្តកោះកុង គឺជាការធ្វើអាជីវកម្មទៅលើធនធានធម្មជាតិរបស់កម្ពុជាដោយមិនទៀងទាត់ ដែលផ្ដល់ផលប្រយោជន៍តិចតួចបំផុតដល់ពលរដ្ឋកម្ពុជា ព្រោះខ្សាច់សម្រាប់នាំចេញ ពុំមានព័ត៌មានចេញផ្សាយជាសាធារណៈអំពីចំណូលនៃការលក់ ឬតម្លៃអាជ្ញាប័ណ្ណដែលរដ្ឋាភិបាលទទួលបាននោះឡើយ។

១០. គេដឹងថាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនធំចំនួនពីរដែលចូលទៅបូមខ្សាច់ដោយផ្ទាល់នៅក្នុងតំបន់ដែលរងផលប៉ះពាល់នោះទទួលការអនុញ្ញាតពីក្រសួងរ៉ែនិងថាមពល តែយ៉ាងណាក្ដីព័ត៌មាន

[14] អង្គការគ្លូលវីដណេស "ប្រទេសសម្រាប់លក់ ៖ តើអ្នកមានអំណាចកម្ពុជាបានក្ដោបក្ដាប់ឧស្សាហកម្មទាញផលពីធនធានធម្មជាតិយ៉ាងដូចម្ដេច?" ខែកុម្ភៈ ឆ្នាំ២០០៩។ អាចរកបានតាមរយៈ៖ globalwitness.org/en/reports/country-sale/

[15] អង្គការគ្លូបលវីដណេស "ការផ្ទេរខ្សាច់ ៖ តើតម្រូវការរបស់សិង្ហបុរីចំពោះខ្សាច់របស់ប្រទេសកម្ពុជា គំរាមកំហែងដល់ប្រព័ន្ធអេកូឡូហ្ស៊ី និងធ្វើឱ្យអន្តរាយដល់អភិបាលកិច្ចល្អយ៉ាងដូចម្ដេច?" (ខែឧសភា ឆ្នាំ២០១០)។ អាចរកបានតាមរយៈ ៖ globalwitness.org/en/archive/shifting-sand-how-singapores-demand-cambodian-sand-threatens-ecosystems-and-undermines-good/

[16] សូមមើលគេហទំព័រ ៖ See http://www.iucn.org/countries/cambodia

[17] ប្រាយអិន កាសថ (Brian Kastl) គង់ គឹមស្រេង ស៊ុន គង់ សុផា នុត ចឺរតាណាគុល ណៃ ព្រហត្ថសាវិទ្ធិ និង អុល វ៉ាន់ "ការសិក្សាអំពីការបំផ្លាញព្រៃកោងកាង និងឈ្លាប់ដែសមុទ្រ ៖ ដំណោះស្រាយនៅសហគមន៍ខេត្តកោះកុង ប្រទេសកម្ពុជា" សហជីពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ សហជីពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN)។

លម្អិតជុំវិញការអនុញ្ញាតនោះមិនច្បាស់លាស់ទាក់ទិនទៅនឹងវិសាលភាពនៃទីតាំងភូមិសាស្ត្រនោះទេ។ ប៉ុន្តែមានការរាយការណ៍ថា ក្រុមហ៊ុនទាំងនោះបាននឹងកំពុងបូមខ្សាច់ចូលទៅក្នុងយ៉ាងជ្រៅ ជាងការអនុញ្ញាតនិងនៅក្រៅទីតាំងភូមិសាស្ត្រជាក់ស្តែងដែលជាការរំលោភទៅលើលក្ខខណ្ឌអនុញ្ញាត។ ក្រសួងរ៉ែនិងថាមពលនិងក្រុមហ៊ុនទាំងពីរនេះបដិសេធថាពួកគេមិនបានរំលោភទៅលើលក្ខខណ្ឌអនុញ្ញាតនោះទេ។ ជាងនេះទៅទៀត បើទោះជាមានការតម្រូវផ្នែកច្បាប់ឱ្យធ្វើការវាយតម្លៃពីហេតុប៉ះពាល់បរិស្ថានក្រោមច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិក្តី ក៏លទ្ធផលនៃការវាយតម្លៃនេះមិនត្រូវបានគេចេញផ្សាយជាសាធារណៈ ហើយសហគមន៍មូលដ្ឋានលើកឡើងថាពុំមានការធ្វើអធិការកិច្ចផ្លូវការនៅក្នុងតំបន់នោះឡើយ។ ក្រសួងរ៉ែនិងថាមពលមិនដែលធ្វើរបាយការណ៍អំពីទំនប់វារីអគ្គិសនីជាសាធារណៈនៅមុនពេលផ្តល់អាជ្ញាប័ណ្ណបូមខ្សាច់ឡើយ។ ប្រការនេះមិនអាចធ្វើឱ្យសហគមន៍ដែលរងផលប៉ះពាល់ សង្គមស៊ីវិល និងមន្ត្រីអនុវត្តច្បាប់ដឹងថាតើក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណទាំងនេះគោរពតាមច្បាប់ដែរ ឬក៏អត់នោះទេ។ ទោះបីជាបញ្ហានេះត្រូវបានសង្គមស៊ីវិល និងយ៉ាងហោចណាស់សមាជិករដ្ឋសភាម្នាក់បានលើកឡើងម្តងហើយម្តងទៀតក៏ដោយ ក៏របាយការណ៍សំខាន់ទាំងនេះនៅតែស្ថិតនៅក្នុងភាពសម្ងាត់។

១១.យុទ្ធនាការរបស់អង្គការមាតាធម្មជាតិជំទាស់ទៅនឹងការបូមខ្សាច់ក្នុងខេត្តកោះកុងមានការចូលរួមពីសកម្មជនរបស់ខ្លួនក្នុងបំណងពង្រឹងអំណាចដល់សហគមន៍មូលដ្ឋានដើម្បីចាត់វិធានការផ្ទាល់ដោយសន្តិវិធីជំទាស់ទៅនឹងការបូមខ្សាច់ដែលបង្កផលប៉ះពាល់ និងខុសច្បាប់នៅដែសមុទ្រខេត្តកោះកុង។ យុទ្ធនាការនោះត្រូវបានប្រមូលផ្តុំដោយពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន ហើយមានតែសហគមន៍ខ្លួនឯងទេដែលសម្រេចធ្វើសកម្មភាពបែបណានោះ។ សកម្មជនអង្គការមាតាធម្មជាតិមានគោលបំណងរៀបចំការតវ៉ាដើម្បីធ្វើឱ្យសកម្មភាពរបស់សហគមន៍មូលដ្ឋានមានប្រសិទ្ធភាពតាមដែលអាចធ្វើទៅបានហើយគ្រប់ពេលប្រព្រឹត្តទៅដោយសន្តិវិធីស្របតាមគោលការណ៍មូលដ្ឋានរបស់អង្គការមាតាធម្មជាតិ។

១២. អង្គការមាតាធម្មជាតិបានចូលរួមផងដែរជាមួយស្ថាប័នរដ្ឋាភិបាលក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់បង្កឡើងដោយការបូមខ្សាច់ក្នុងតំបន់។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ សកម្មជនអង្គការមាតាធម្មជាតិ ឈ្មោះ សន ចាន់ដារ៉ា ដឹម គុណឌី និង ចេក នីត្រា ត្រូវបានចាប់ខ្លួនខណៈកំពុងព្យាយាមដាក់ញត្តិទៅកាន់រដ្ឋសភាជំទាស់ទៅនឹងការបូមខ្សាច់ក្នុងរាជធានីភ្នំពេញ។ បញ្ហាបូមខ្សាច់នេះទទួលបានការគាំទ្រពីលោក សុន ឆ័យ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិ ដោយនៅថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១៥ បានផ្ញើលិខិតមួយច្បាប់ទៅកាន់នាយករដ្ឋ មន្ត្រី ហ៊ុន សែន ដោយស្នើនាយករដ្ឋមន្ត្រីឱ្យធ្វើអន្តរាគមន៍ដើម្បី *"បង្ហាញព័ត៌មានទាក់ទិនទៅនឹងការបូមខ្សាច់"* និងសកម្មភាពបូមខ្សាច់ដែល *"បង្កផលប៉ះពាល់ទ្រង់ទ្រាយធំ"*[18]។

[18] អូន ភាព និងគ្រីស ម៉ូលើ "តំណាងរាស្ត្រ និងអង្គការចង់ឱ្យរដ្ឋាភិបាលស៊ើបអង្កេតករណីបូមខ្សាច់" សារព័ត៌មាន *ខេមបូឌា ដេលី* ថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៥។ អាចរកបានតាមរយៈ http://bit.ly/1r9juU2 ។

*ជនត្រូវចោទ ៖ សាន់ ម៉ាឡា ទ្រី សុវិគា ស៊ីម សំណាង និង អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន*

១៣. ជនត្រូវចោទទាំងបួននាក់គឺជាមនុស្សសំខាន់នៅក្នុងអង្គការមាតាធម្មជាតិ។ លោក សាន់ ម៉ាឡា អាយុ ២៤ ឆ្នាំ និង ស៊ីម សំណាង អាយុ ២៩ ឆ្នាំ គឺជាពលរដ្ឋកម្ពុជា និងជាសហស្ថាបនិករបស់អង្គការមាតាធម្មជាតិ។ លោក ទ្រី សុវិគា អាយុ ២៦ ឆ្នាំ គឺជាពលរដ្ឋកម្ពុជានិងជាសកម្មជនអង្គការមាតាធម្មជាតិ។ ជនត្រូវចោទទីបួនគឺលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន អាយុ ៣៥ ឆ្នាំ ជា ជនជាតិអេស្ប៉ាញ ដែលជាសហស្ថាបនិកនិងជានាយករបស់អង្គការមាតាធម្មជាតិ។

១៤. បច្ចុប្បន្ននេះលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស កំពុងនិរទេសខ្លួនពីកម្ពុជា បន្ទាប់ពីត្រូវបានបញ្ជូនចេញកាលពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ក្រោយពីមានការបដិសេធទិដ្ឋាការរបស់លោក ដែលនេះប្រហែលជាមកពីភាពសកម្មជំទាស់ទៅនឹងការសាងសង់ទំនប់វារីអគ្គិសនីឆាយអារ៉ែងក្នុងខេត្តកោះកុង[19]។ លោក ហ្គុនហ្សាឡេហ្ស ដាវីដសុន ត្រូវបានបដិសេធម្តងហើយម្តងទៀតចូលមកកាន់កម្ពុជា ហើយក្រសួងការបរទេសនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ បានចេញអនុស្សរណៈផ្ទៃក្នុងជាបន្ទាន់នៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ណែនាំមន្ត្រីតាមព្រំដែនទាំងអស់មិនអនុញ្ញាតឱ្យលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ចូលមកក្នុងប្រទេសនោះទេ។

១៥. អន្តរាគមន៍នេះបានកើតឡើងបន្ទាប់ពីមានដីកាកោះ និងដីកាចាប់ខ្លួនលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ចំពោះបទចោទនាបច្ចុប្បន្ននេះ។ យោងតាមមាត្រា ៥២០ នៃក្រមព្រហ្មទណ្ឌ ដែលចែងពី "បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ" មន្ត្រីសាធារណៈណាដែលមិនគោរពតាមសេចក្តីបង្គាប់របស់តុលាការដូចជា ដីកាចាប់ខ្លួន ឬដីកាកោះ គឺជាការប្រព្រឹត្តបទល្មើស និងអាចទទួលទោសជាប់ពន្ធនាគារពី ២ ឆ្នាំដល់ ៥ ឆ្នាំ។ ភាពមិនស៊ីសង្វាក់គ្នាក្នុងការបំពេញតួនាទីរបស់ មន្ត្រីរដ្ឋាភិបាលកំពុងរារាំងលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ក្នុងការចូលខ្លួនតាមដីកាកោះ។

## ៣ សាចការនៃអង្គហេតុ

*ស៊ីម សំណាង ទ្រី សុវិគា និង សាន់ ម៉ាឡា*

១៦. អង្គហេតុដែលបង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់នេះគឺមិនច្បាស់លាស់ទាល់តែសោះ ដែលធ្វើឱ្យកាន់តែមានការព្រួយបារម្ភខ្លាំងឡើងជុំវិញមូលដ្ឋានផ្លូវច្បាប់របស់ពួកគេ ហើយជាពិសេស ការឃុំខ្លួនបណ្តោះអាសន្នដែលមានថិរវេលាយូរទៅលើសកម្មជនអង្គការមាតាធម្មជាតិចំនួនបីនាក់។

១៧. ករណីសំខាន់នៅក្នុងការចោទប្រកាន់នេះពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងអំឡុងពេលយុទ្ធនាការនៅចន្លោះថ្ងៃទី២៦ និងទី២៨ ខែកក្កដា ឆ្នាំ២០១៥។ សកម្មជនអង្គការមាតាធម្មជាតិចំនួនប្រាំបីរូបព្រមទាំងសហគមន៍មូលដ្ឋានក្នុងភូមិអណ្តូងទឹកបានជំទាស់ទៅនឹងការបូមខ្សាច់ដែល

[19] គាត ឧត្តម ម៉ៃ ទិត្យថារ៉ា Daniel Pye and Griff Tapper "សកម្មជនការពារបរិស្ថានដ៏លេចធ្លោត្រូវបានបញ្ជូនចេញ" សារព័ត៌មាន *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥។ អាចរកបានតាមរយៈ ៖ http://bit.ly/1Rh7gUF ។

កំពុងធ្វើសកម្មភាព ប៉ុន្តែសកម្មជនទាំងអស់នេះមិនមានវត្តមាននៅរៀងរាល់ថ្ងៃតវ៉ានោះទេ។ ប្រជាសហគមន៍ចន្លោះពី ៦០ នាក់ ដល់ ១៥០ នាក់បានចូលរួមតវ៉ារយៈពេលជាងបីថ្ងៃ។ នៅថ្ងៃទី២៦ ខែកក្កដា ប្រជាពលរដ្ឋមួយក្រុមមានគ្នាជិត ៦០ នាក់បានប្រមូលផ្តុំគ្នាទាំងព្រឹកនៅស្ពានអណ្តូងទឹកហើយបន្ទាប់មកបានប្រើប្រាស់ទូកនេសាទតូចចន្លោះពី ៥ ទៅ ១០ ទូកធ្វើដំណើរតាមដងទន្លេឆ្ពោះទៅកាន់សាឡង់បូមខ្សាច់។ សកម្មភាពពេលនេះធ្វើឡើងស្រដៀងគ្នាទៅនឹងសកម្មភាពនៅថ្ងៃទី២៧ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ដែរ បើទោះជាក្រុមប្រជាពលរដ្ឋមានទ្រង់ទ្រាយផ្សេងគ្នាធ្វើឡើងនៅកាលបរិច្ឆេទខុសគ្នាក៏ដោយ។ គោលបំណងរបស់ពួកគេគឺដើម្បីរៀបចំការតវ៉ា និងស្នើឱ្យបញ្ឈប់នូវសកម្មភាពបូមខ្សាច់ពីសំណាក់ក្រុមហ៊ុនទទួលសិទ្ធិផ្តាច់មុខខាងលើ។ ក្រុមប្រជាពលរដ្ឋបានអំពាវនាវម្តងហើយម្តងទៀតឱ្យកម្មករនៅលើសាឡង់បូមខ្សាច់បញ្ឈប់សកម្មភាពបូមខ្សាច់ និងចាកចេញពីតំបន់នោះ។ ជាថ្មីម្តងទៀត អស់រយៈពេលជាងបីថ្ងៃ សមាជិកក្រុមនោះបានជិះទូកទៅកាន់សាឡង់បូមខ្សាច់នោះក្នុងបំណងស្នើឱ្យកម្មករលើទូកនោះបញ្ឈប់សកម្មភាពបូមខ្សាច់។ ក្នុងការតវ៉ានោះ គ្មានការលើកឡើងថាអ្នកតវ៉ាបង្កឱ្យមានការខូចខាតដល់សាឡង់ ឬសម្ភារៈបូមខ្សាច់នោះឡើយ។ ប៉ុន្តែ មានការលើកឡើងថា អ្នកតវ៉ាមួយចំនួនបានគំរាមកំហែង និងធ្វើឱ្យខូចខាតសាឡង់ បើសិនពួកកម្មករមិនព្រមចាកចេញពីតំបន់នោះ។ ប៉ុន្តែ របាយការណ៍ទាំងនេះមិនច្បាស់លាស់ និងមានភាពមិនស្របគ្នាជាច្រើនក្នុងភស្តុតាងពាក់ព័ន្ធដែលបង្ហាញខាងក្រោម។

១៨. ព្រឹត្តិការណ៍ទាំងនេះបានកើតឡើងនៅតាមដងព្រែកដែលមានចម្ងាយប្រមាណ ២០ គីឡូម៉ែត្រ មានការចូលរួមដោយសាឡង់បូមខ្សាច់ធំៗចំនួន ១០ គ្រឿង និងទូកនេសាទតូចៗជាច្រើនទៀតរបស់សហគមន៍។ កាលៈទេសៈទាំងនេះពិបាកណាស់គ្មានការសន្និដ្ឋានឱ្យច្បាស់លាស់ពាក់ព័ន្ធទៅនឹងសកម្មភាព និងពាក្យសម្តីរបស់បុគ្គល កាលបរិច្ឆេទ និងទីតាំងជាក់លាក់ណាមួយ។ បន្ថែមទៅលើភាពលំបាកនេះ គឺកង្វះភាពច្បាស់លាស់ និងភាពមិនស៊ីសង្វាក់គ្នាទាំងស្រុងតាមរយៈសម្តីរបស់សាក្សី។

១៩. អ្នកតវ៉ាត្រូវបានបំបែកគ្នាជាក្រុមតូចៗ និងបានពង្រាយគ្នាទៅតាមកន្លែងខុសៗគ្នានៅតាមដងព្រែក ហេតុនាំឱ្យមានការតវ៉ាតូចៗជាច្រើនបានកើតឡើងក្នុងទីតាំងខុសគ្នានៅពេលនោះ។ សាក្សីទាំងនេះមិនបានលើកឡើងឱ្យស៊ីសង្វាក់គ្នាពីទីកន្លែងដែលបទល្មើសបានកើតឡើង ថាតើកើតឡើងនៅលើសាឡង់មួយណា នៅថ្ងៃណា និងនៅម៉ោងប៉ុន្មាននោះឡើយ។

២០. នៅចន្លោះពីថ្ងៃ៣០ ខែកក្កដា និងថ្ងៃទី១៧ ខែសីហា ក្រសួងរ៉ែ និងថាមពលបានអះអាងម្តងហើយម្តងទៀតក្នុងកិច្ចសន្ទនាជាមួយអង្គការមាតាធម្មជាតិ និងសហគមន៍មូលដ្ឋានថាការបូមខ្សាច់នោះស្របច្បាប់ អនុលោមតាមលិខិតអនុញ្ញាតដែលនៅមានសុពលភាពរបស់ក្រុមហ៊ុន និងបានធ្វើការវាយតម្លៃពីហេតុប៉ះពាល់បរិស្ថានរួចរាល់ហើយ។ ប៉ុន្តែលទ្ធផលនៃការវាយតម្លៃពីហេតុប៉ះពាល់បរិស្ថានមិនត្រូវបានគេចេញផ្សាយជាសាធារណៈ ឬបង្ហាញដល់សហគមន៍ដែលរងផលប៉ះពាល់ទាំងនោះឡើយ បើ

ទោះជាមានការស្នើពីលោក សុន ឆ័យ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិក្តី[20] និងសហគមន៍មូលដ្ឋាន ដែលលើកឡើងថាមិនបានធ្វើការសិក្សាពីផលប៉ះពាល់ឡើយ។

២១. បន្ទាប់ពីមានការបញ្ឈប់សកម្មភាពផ្នែកសាឡង់បូមខ្សាច់ នៅថ្ងៃទី១២ ខែសីហា ក្រុមហ៊ុនខាងលើបន្តសកម្មភាពបូមខ្សាច់នៅព្រែកអណ្តូងទឹក និងមានវត្តមានរបស់នគរបាលជាច្រើននាក់ ដែលកាន់តែនាំឱ្យមានការតវ៉ាបន្ថែមទៀតពីសំណាក់សហគមន៍មូលដ្ឋាន។ មានការលើកឡើងមួយចំនួនថាការចោទប្រកាន់អាចពាក់ព័ន្ធនឹងការតវ៉ានេះ បើទោះជា ទ្រី សុវិគា ដែលជាជនត្រូវចោទម្នាក់ក្នុងចំណោមអ្នកជាប់ឃុំបីនាក់ មិនមានវត្តមាននៅថ្ងៃនោះក៏ដោយ។ នៅថ្ងៃទី១៤ ខែសីហា នគរបាលបានចេញលិខិតកោះហៅ សាន់ ម៉ាឡា ទ្រី សុវិគា និង យឺន ឪនិត ដើម្បីសាកសួរ។ អ្នកទាំងបីនាក់នោះមិនបានគោរពតាមលិខិតនោះឡើយ ព្រោះពួកគាត់បារម្ភពីការចាប់ខ្លួន ឬបង្កើតទឡ្ហីករណ៍ដាក់បន្ទុក ដោយសារពីមុនធ្លាប់មានករណីស្រដៀងគ្នានេះរួចមកហើយ។[21] ស្របពេលជាមួយគ្នានេះ មន្ត្រីកងរាជអាវុធហត្ថជាច្រើននាក់ និងគណៈប្រតិភូមកពីក្រសួងរ៉ែ និងថាមពលបានមកដល់ភូមិអណ្តូងទឹក ដែលបានដឹកនាំដោយលោក ទិត្យ ឪណា រដ្ឋលេខាធិការក្នុងគោលបំណងធ្វើអធិការកិច្ចស្ថានការណ៍នោះ។ នៅថ្ងៃទី១៥ ខែសីហា សកម្មជនដែលត្រូវបានតុលាការកោះហៅចំនួនពីរនាក់ គឺ សាន់ ម៉ាឡា និង ទ្រី សុវិគា ដែលជាអ្នកពាក់ព័ន្ធនឹងស្ពានអណ្តូងទឹក ដោយបានស្រែកហៅនគរបាលឱ្យមកចាប់ខ្លួន។ ពួកគេបានបង្ហោះរូបភាពរបស់ខ្លួននៅលើទំព័រហ្វេសប៊ុករបស់អង្គការមាតាធម្មជាតិដើម្បីបញ្ជាក់ការគោរពទៅនឹងគោលបំណងរបស់អាជ្ញាធរ និងដើម្បីទាញចំណាប់អារម្មណ៍ចំពោះការបង្ក្រាបរបស់អាជ្ញាធរទៅលើការតវ៉ាជំទាស់ទៅនឹងការបូមខ្សាច់នៅក្នុងតំបន់នោះ។

២២. នៅថ្ងៃទី១៧ ខែសីហា សាន់ ម៉ាឡា ទ្រី សុវិគា និងស៊ីម សំណាង ត្រូវបានចាប់ខ្លួន។ សាន់ ម៉ាឡា និង ទ្រី សុវិគា ត្រូវបានចាប់ខ្លួននៅភូមិអណ្តូងទឹក ចំណែក ស៊ីម សំណាង ត្រូវបានចាប់ខ្លួននៅភូមិតាមាក់។ ពួកគេត្រូវបានចោទប្រកាន់ពីបទ *"គំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ"* ក្រោមមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ។ អ្នកទាំងនោះត្រូវបានឃុំខ្លួននៅពន្ធនាគារខេត្តកោះកុងចាប់តាំងពីពេលនោះមក មានន័យថា ខណៈពេលសរសេរអត្ថបទនេះក្នុងខែមិថុនា ឆ្នាំ២០១៦ ពួកគាត់បានជាប់ឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលដប់ខែមកហើយ។ ក្រោយមកលេចឮថាបណ្តឹងនោះធ្វើឡើងដោយកម្មករក្រុមហ៊ុនបូមខ្សាច់ទាំងនោះ។ ពាក្យបណ្តឹងនោះព្រមទាំងបានទាមទារសំណងជាទឹកប្រាក់ចំនួន ១០០.០០០ ដុល្លារអាមេរិក។

### *អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន*

---

[20] អូន ភាព និងគ្រីស មឹលល័រ ( Chris Mueller ) តំណាងរាស្ត្រ និងអង្គការក្រៅរដ្ឋាភិបាល ចង់ឲ្យរដ្ឋាភិបាលសាកសួរពីការបូមខ្សាច់ សារព័ត៌មានខេមបូឌា ដេលី (ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៥) អាចរកបានតាមរយៈ ៖ http://bit.ly/28IqjEs

[21] ជាឧទាហរណ៍ សូមមើលកំណត់ត្រាសង្ខេបរបស់ ម.ស.ម.ក ស្តីពី "ការដោះលែងដោយមានលក្ខខណ្ឌលើអ្នកការពារសិទ្ធិមនុស្ស រំលោភលើសិទ្ធិជាមូលដ្ឋាននៃសេរីភាពខាងការបញ្ចេញមតិ និងជួបប្រជុំ ខែកុម្ភៈ ឆ្នាំ២០១៤។ អាចរកបានតាមរយៈ ៖ http://bit.ly/1su2md6

២៣. ទោះបីជាលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន ត្រូវបាននិរទេសចេញ និងហាមចូលមកកាន់ប្រទេសកម្ពុជានៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ រយៈពេលប្រាំមួយខែនៅមុនព្រឹត្តិការណ៍នោះក៏ដោយ នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ក៏គាត់ត្រូវបានចោទប្រកាន់ជាអ្នកសមគំនិតក្នុងករណីនេះក្រោមមាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ។ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បានស្នើសុំជាសាធារណៈជាច្រើនលើកច្រើនសារដើម្បីអនុញ្ញាតឱ្យរូបគាត់បានវិលត្រឡប់មកកាន់ប្រទេសកម្ពុជាដើម្បីការពារខ្លួននៅក្នុងតុលាការកម្ពុជា។ កិច្ចប្រឹងប្រែងរួមទាំងការដាក់សំណើសុំទិដ្ឋាការតាមប្រព័ន្ធអ៊ីនធឺណិតដែលត្រូវបានផ្តល់ឱ្យហើយ តែក្រោយមកត្រូវបានក្រសួងការបរទេសបដិសេធវិញ។ អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ពីមុនធ្លាប់បានដាក់លិខិតទៅកាន់រដ្ឋមន្រ្តីក្រសួងមហាផ្ទៃដើម្បីស្នើសុំទិដ្ឋាការ ប៉ុន្តែបុគ្គលិករដ្ឋបាលក្រសួងបានបដិសេធទទួលយកលិខិតនោះ។ អង្គការសង្គមស៊ីវិលចំនួន ២២ បានចេញសេចក្តីថ្លែងការណ៍រួមផងដែរដោយអំពាវនាវឱ្យរដ្ឋាភិបាលផ្តល់ការអនុញ្ញាតដល់អាឡិចហ្សង់ដ្រូដើម្បីអាចការពារខ្លួនដោយផ្ទាល់នៅក្នុងតុលាការ អនុលោមតាមសិទ្ធិរបស់គាត់ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[22]។ ទោះជាយ៉ាងណា រដ្ឋាភិបាលនិងក្រសួងមហាផ្ទៃបានបញ្ជាក់យ៉ាងច្បាស់ថាពួកគេគ្មានបំណងអនុញ្ញាតឱ្យលោក ហ្គុនហ្សាឡេហ្ស ដាវីដសុន វិលត្រឡប់មកកាន់ប្រទេសកម្ពុជាជាថ្មីឡើយ។

## ៤ អង្គច្បាប់

២៤. បញ្ហាច្បាប់ដែលបានលើកឡើងក្នុងករណីនេះពាក់ព័ន្ធនឹងបទល្មើសព្រហ្មទណ្ឌគឺការគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងនាមជាអ្នកសមគំនិតក្នុងបទល្មើស ការតម្រូវឱ្យមានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រទៅលើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ សិទ្ធិសេរីភាពខាងការបញ្ចេញមតិ ការប្រមូលផ្តុំ និងការជួបប្រជុំ សិទ្ធិមិនត្រូវបានឃុំខ្លួនតាមអំពើចិត្ត នឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌រួមទាំងសិទ្ធិការពារខ្លួនផ្ទាល់។ ច្បាប់ដែលអនុវត្តពាក់ព័ន្ធនៅក្នុងបញ្ហាទាំងនេះនឹងមានគូសបញ្ជាក់ដូចខាងក្រោម។

***បទល្មើសនៃការគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ***

២៥. មាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌពន្យល់បទល្មើសនៃ "*ការគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ*" គឺជា ៖

> "*អំពើគំរាមកំហែង តាមមធ្យោបាយណាក៏ដោយ ថានឹងប្រព្រឹត្តការបំផ្លិចបំផ្លាញ ការធ្វើឱ្យទ្រុឌទ្រោម ឬការធ្វើឱ្យខូចខាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និង*

[22] ម.ស.ម.ក សេចក្តីថ្លែងការណ៍រួម ៖ អង្គការសង្គមស៊ីវិលសូមប្រកាសគាំទ្រអង្គការមាតាធម្មជាតិ និងថ្កោលទោសចំពោះការបង្ក្រាបទៅលើអង្គការនេះ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦។ អាចរកបានតាមរយៈ ៖ http://bit.ly/1Y4P9TF

*ពិន័យជាប្រាក់ពី ២០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ប្រសិនបើការគំរាមកំហែងនេះមានភ្ជាប់នូវបញ្ជាឱ្យបំពេញ ឬមិនបំពេញកិច្ចអ្វីមួយ»*[23]។

២៦. និយមន័យនេះអាចត្រូវបានបំបែកជាធាតុផ្សំមួយចំនួនដើម្បីភ្ជាប់ជនណាមួយទៅនឹងបទល្មើសនេះ រួមមាន (១) ជនជាប់ចោទត្រូវតែគំរាមកំហែងជាក់ស្តែង។ អនុលោមតាមបទប្បញ្ញត្តិស្រដៀងគ្នានេះ ក្នុងមាត្រា ២២២ -១៨ នៃក្រមព្រហ្មទណ្ឌបារាំង ការគំរាមនេះត្រូវតែធ្វើឡើងតាមសំដីវិជ្ជមាន និងមិនអាចគ្រាន់តែជាការប្រហែល ឬមិនច្បាស់លាស់នោះទេ (២) ការគំរាមត្រូវតែថ្លែងឱ្យបានជាក់លាក់ និងច្បាស់លាស់ថាជនជាប់ចោទនឹងធ្វើសកម្មភាពបង្កការបំផ្លិចបំផ្លាញ ការធ្វើឱ្យមានឱនភាព ឬការធ្វើឱ្យខូចខាតដល់ទ្រព្យសម្បត្តិ ហើយ (៣) ការគំរាមកំហែងនេះត្រូវតែបង្ហាញថាអ្នកដែលទទួលបញ្ជានោះនឹងជួបបញ្ហាប្រសិនបើមិនអនុវត្តតាម។ លក្ខខណ្ឌសំខាន់ក្នុងធាតុផ្សំទាំងនេះរួមមាន ការគំរាមកំហែងត្រូវតែជាក់លាក់ហើយត្រូវតែជាប់ពាក់ព័ន្ធយ៉ាងច្បាស់ទៅនឹងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងត្រូវបានចាត់ទុកថាជាផលវិបាកដោយផ្ទាល់ពីការបដិសេធក្នុងការគោរពតាមបង្គាប់។

### *ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក្នុងនាមជាអ្នកសមគំនិតក្នុងបទល្មើស*

២៧. មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌឱ្យនិយមន័យ "*អ្នកសមគំនិត*" យ៉ាងដូច្នេះ ៖

> "*ត្រូវចាត់ទុកថាជាអ្នកសមគំនិតក្នុងបទឧក្រិដ្ឋឬបទមជ្ឈិមចំពោះបុគ្គលណាដែលជួយសម្រួលដោយចេតនាដល់ការប៉ុនប៉ង ឬការសម្រេចបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះ ដោយផ្តល់ជំនួយ ឬការឧបត្ថម្ភរបស់ខ្លួន។*
>
> *អ្នកសមគំនិតនៃបទឧក្រិដ្ឋ ឬ បទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ*[24]។"

និយមន័យនេះអាចត្រូវបានបំបែកទៅជាធាតុផ្សំមួយចំនួនដូចជា ៖ (១) ត្រូវតែមានសកម្មភាពជាក់ស្តែងរបស់ជនជាប់ចោទដែលជួយ ឬ ផ្តល់ជំនួយ (២) អ្នកសមគំនិតត្រូវតែបានធ្វើសកម្មភាពដោយមានចេតនាជួយចារីនោះក្នុងការប្រព្រឹត្តសកម្មភាពព្រហ្មទណ្ឌ និងដោយដឹងច្បាស់ជាមុនថាពួកគេអាចធ្វើសកម្មភាពដូច្នោះ (៣) សកម្មភាពព្រហ្មទណ្ឌត្រូវតែបានប្រព្រឹត្តដោយចារីដើម្បីឱ្យការទទួលខុសត្រូវអ្នកសមគំនិតកើតឡើង។

### *ស្តង់ដារនៃភស្តុតាងចំពោះបទល្មើសព្រហ្មទណ្ឌ*

២៨. ស្តង់ដារនៃភស្តុតាងកំណត់ពីភាពច្បាស់លាស់ដែលស្ថាប័នអយ្យការត្រូវបង្ហាញពីធាតុផ្សំនៃបទល្មើស។ នៅប្រទេសកម្ពុជា ជនត្រូវចោទពីបទល្មើសព្រហ្មទណ្ឌ ធាតុផ្សំនៃបទល្មើសទាំងអស់ត្រូវតែបង្ហាញនូវភស្តុតាងឱ្យបានច្បាស់លាស់ផុតពីវិមតិសង្ស័យ។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងពីលក្ខខណ្ឌស្តង់ដារនៃភស្តុតាងដើម្បីកាត់ទោសបុគ្គលណាម្នាក់ពីបទល្មើសព្រហ្មទណ្ឌ ៖

[23] ក្រមព្រហ្មទណ្ឌ មាត្រា ៤២៤ ។

[24] ក្រមព្រហ្មទណ្ឌ មាត្រា ២៩ ។

*"វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ[25]។"*

នេះគឺជាលក្ខខណ្ឌតម្រូវបឋមសម្រាប់អយ្យការគោរពតាម និងមានលក្ខណៈកាន់តែតឹងរ៉ឹងជាងការ "ផុតពីការសង្ស័យដោយសមហេតុផល" ដែលជាស្តង់ដារមួយជារឿយៗត្រូវបានអនុវត្តនៅក្នុងយុត្តាធិការខំម៉ុនឡ (Common Law)។ ម្យ៉ាងទៀត យោងតាមមាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នេះគឺជាកាតព្វកិច្ចរបស់ចៅក្រមជំនុំជម្រះក្នុងការពិចារណាទៅលើទាំងភស្តុតាងដាក់បន្ទុកនិងភស្តុតាងដោះបន្ទុក មានន័យថាភស្តុតាងទាំងអស់ដែលជាប់ពាក់ព័ន្ធនឹងជនត្រូវចោទដែលគ្មានទោសត្រូវតែថ្លឹងថ្លែងឱ្យស្មើគ្នាទៅនឹងភស្តុតាងដាក់ពិរុទ្ធ។

***ការដាក់បន្ទុកចំពោះបទល្មើសព្រហ្មទណ្ឌ***

២៩. ការដាក់បន្ទុកកំណត់ឱ្យភាគីក្នុងដំណើរការនីតិវិធីមានភស្តុតាងបង្ហាញនៅក្នុងសំណុំរឿង។ ក្នុងករណីព្រហ្មទណ្ឌ ការដាក់បន្ទុកគឺស្ថិតនៅលើស្ថាប័នអយ្យការ ដោយអយ្យការត្រូវតែផ្តល់ភស្តុតាងបង្ហាញពីធាតុផ្សំនៃបទល្មើសទាំងអស់រហូតទាល់តែមានភស្តុតាងដែលតម្រូវតាមស្តង់ដារ។ នេះជាធាតុផ្សំសំខាន់មួយនៃសិទ្ធិត្រូវបានគេចាត់ទុកថាគ្មានទោសរហូតទាល់តែបានបង្ហាញពិរុទ្ធភាព។ ក្នុងក្រមព្រហ្មទណ្ឌ គ្មានការដាក់បន្ទុកទៅលើជនត្រូវចោទដើម្បីបង្ហាញថាការចោទទៅលើពួកគេគឺមិនពិតនោះឡើយ។ ប្រសិនបើភស្តុតាងខ្សោយពេកមិនអាចបង្ហាញធាតុផ្សំនៃករណីនេះ ដូច្នេះតុលាការត្រូវតែច្រានចោលការចោទប្រកាន់ ដោយពុំចាំបាច់ពិចារណាថាតើជនត្រូវចោទបានបង្ហាញភស្តុតាងណាមួយនោះទេ។

៣០. សិទ្ធិត្រូវបានចាត់ទុកថាគ្មានទោសរហូតដល់មានការបង្ហាញភស្តុតាងថាមានទោសដែលមានចែងនៅក្នុងច្បាប់អន្តរជាតិតាមរយៈមាត្រា ១១ (១) នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ("ស.ស.ស.ម") និងមាត្រា ១៤ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ក.ស.អ.ព.ន") ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ១៩៩២ ។ សិទ្ធិទាំងនេះត្រូវបានដាក់បញ្ចូលក្នុងច្បាប់កម្ពុជាស្របតាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ ដែលបានទទួលស្គាល់តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧[26]។ នៅថ្នាក់តំបន់ សិទ្ធិត្រូវបានគេចាត់ទុកថាគ្មានទោសត្រូវបានទទួលស្គាល់ក្នុងមាត្រា២០(១)នៃសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន។ សច្ចធារណ៍នៃភាពគ្មានទោសមានចែងផងដែរក្នុងមាត្រា ៣៨ (៧) នៃរដ្ឋធម្មនុញ្ញដែលមានចែងនៅក្នុងកថាខណ្ឌ ២៩ ខាងលើ។

***សិទ្ធិទទួលបានសេរីភាព និងសិទ្ធិមិនត្រូវបានគេឃុំខ្លួនតាមអំពើចិត្ត***

---

[25] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨ ។

[26] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩១/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)។

៣១. សិទ្ធិទទួលបានសេរីភាពត្រូវបានការពារយ៉ាងរឹងមាំក្រោមច្បាប់សិទ្ធិមនុស្សជាតិនិងអន្តរជាតិ។ នៅថ្នាក់តំបន់ សិទ្ធិនេះត្រូវបានទទួលស្គាល់ក្នុងមាត្រា១២នៃសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន។ មាត្រា ៩ នៃ ក.ស.អ.ព.ន ចែងថា ៖

*"១. ជនគ្រប់រូបមានសិទ្ធិសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ គ្មានជនណាម្នាក់ត្រូវបានដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងក្នុងច្បាប់»។*

...

*"៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ និងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការក្នុងរយៈពេលយ៉ាងខ្លីបំផុត និង**ត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្របឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្សដើម្បីរង់ចាំការជំនុំជម្រះមិនមែនជាវិធានទូទៅទេ** ប៉ុន្តែការឱ្យនៅក្រៅឃុំត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់កាលដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការអនុវត្តសាលក្រម។"*

៣២. សិទ្ធិមិនត្រូវបានគេឃុំខ្លួនតាមអំពើចិត្ត និងការផ្តល់យុត្តិកម្មរឹងមាំសម្រាប់ការកំណត់ឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានការពារយ៉ាងខ្លាំងផងដែរនៅក្នុងច្បាប់កម្ពុជា។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងថា ៖

*"ការចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់[27]។"*

៣៣. ទោះបីជានៅក្នុងករណីចាំបាច់ខ្លះត្រូវធ្វើការឃុំខ្លួនបណ្តោះអាសន្នដើម្បីជួយរៀបចំឱ្យមានយុត្តិធម៌ត្រឹមត្រូវដើម្បីការពារជនរងគ្រោះ និងសាក្សីក៏ដោយ ក៏ការឃុំខ្លួនបណ្តោះអាសន្នហួសហេតុបានរឹតត្បិតយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិទទួលបានសេរីភាព និងការសន្មតពីភាពគ្មានទោស។ មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌគូសបញ្ជាក់ពីលក្ខខណ្ឌសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នដែលសមហេតុផលតាមច្បាប់ដូចខាងក្រោម ៖

*"ការឃុំខ្លួនបណ្តោះអាសន្ន អាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់ ៖*

*១. ដើម្បីបញ្ចប់បទល្មើស ឬដើម្បីបង្ការបទល្មើសកុំឱ្យកើតជាថ្មី។*

*២. ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សីឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យត្រូវរ៉ូវគ្នារវាងជនត្រូវចោទនិងអ្នកសមគំនិត។*

*៣. ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។*

---

[27] រដ្ឋធម្មនុញ្ញ មាត្រា ៣៨ ។

*៤. ដើម្បីធានាក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី។*

*៥. ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ។*

*៦. ដើម្បីធានាក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស[28]។"*

ដូចបានគូសបញ្ជាក់តាមលក្ខខណ្ឌទាំងនេះ ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើទៅបានក្នុងជម្រើសចុងក្រោយបង្អស់ ចៅក្រមគួរចាប់ផ្ដើមធ្វើការសន្មតពីភាពគ្មានទោសទៅលើជនជាប់ចោទ ហើយគួរដោះលែងពួកគេឱ្យមានសេរីភាពរហូតដល់ពេលជំនុំជម្រះ ឬគួរពិចារណាពីការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ (កំណត់លក្ខខណ្ឌលើសេរីភាពរបស់ជនជាប់ចោទម្នាក់ៗរហូតដល់ពេលជំនុំជម្រះ) មុនពេលចៅក្រមពិចារណាឃុំខ្លួនបណ្ដោះអាសន្ន។ ដរាបណាការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ មិនអាចដោះស្រាយបញ្ហាទាំងអស់ឱ្យបានសមស្រប ទើបត្រូវពិចារណាដល់ការឃុំខ្លួនបណ្ដោះអាសន្នដែលជាការចាំបាច់ និងជាជម្រើសចុងក្រោយ។ សេរីភាពរបស់ជនជាប់ចោទត្រូវតែជាជម្រើសសំខាន់ជានិច្ចជាងការឃុំខ្លួន។

៣៤. ទោះជាយ៉ាងណា ប្រទេសកម្ពុជានៅតែមានអត្រាឃុំខ្លួនបណ្ដោះអាសន្នខ្ពស់។ ជាក់ស្ដែង ក្នុងឆ្នាំ២០១២ សវនាការដែលបានឃ្លាំមើលដោយ ម.ស.ម.ក គឺជនត្រូវចោទត្រូវបានឃុំខ្លួនបណ្ដោះអាសន្នរហូតដល់ ៧០ ភាគរយ។[29] ជាការវិវឌ្ឍគួរឱ្យកត់សម្គាល់មួយ ចាប់តាំងពីខែមីនា ឆ្នាំ២០១៤ មកចៅក្រមត្រូវតម្រូវឱ្យផ្ដល់នូវសំអាងហេតុលម្អិតចំពោះការបដិសេធជនជាប់ចោទឱ្យនៅក្រៅឃុំ ដែលជាចំណាត់ការរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីកាត់បន្ថយចំនួនពលរដ្ឋស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។[30] ទោះបីជាមានការតម្រូវតឹងរ៉ឹងបែបនេះក៏ដោយ ក៏បញ្ហានេះហាក់ដូចជាកាន់តែធ្ងន់ធ្ងរជាងមុន ។ ស្ថិតិរបស់រដ្ឋាភិបាលបង្ហាញថា អ្នកស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នក្នុងពន្ធនាគារកម្ពុជាបានកើនឡើងពី២៤% ទៅ ៣០% នៃចំនួនអ្នកជាប់ឃុំសរុបនៅពាក់កណ្ដាលឆ្នាំ២០១៤ ។[31] ទោះជាយ៉ាងនេះក៏ដោយ អ្នកសង្កេតការណ៍អន្តរជាតិបានដាក់ភាគរយនៃការឃុំខ្លួនបណ្ដោះអាសន្នរហូតដល់ ៦៣,៦ % ជាភាគរយខ្ពស់បំផុតនៅអាស៊ីអាគ្នេយ៍[32]។ ការកំណត់ទោសទណ្ឌឱ្យមានការឃុំខ្លួនបណ្ដោះអាសន្នដែលរាលដាលបែបនេះគឺជារឿយៗកើតឡើងទៅលើអ្នកការពារសិទ្ធិមនុស្សដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ការសន្មត់ទុកជាមុនថាគ្មានទោស។

---

[28] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៥ ។

[29] របាយការណ៍ ប្រចាំឆមាសលើកទីប្រាំរបស់ ម.ស.ម.ក ស្ដីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា"។ អាចរកបានតាមរយៈ ៖ http://bit.ly/1U3bG0w

[30] ឡូរ៉េន ក្រតធឺ ( Lauren Crothers )"ចៅក្រមត្រូវបានតម្រូវឱ្យពន្យល់ពីហេតុផលពីក្រោយការឃុំខ្លួនបណ្ដោះអាសន្ន" ខេមបូឌា ដេលីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤។ អាចរកបានតាមរយៈ ៖ http://bit.ly/1VJXsRI

[31] អាលីស៍ យុឌឌី និង ឆាយ ច័ន្ទនីដា "វិធានឃុំខ្លួនបណ្ដោះអាសន្នត្រូវបានបំពាន" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ។ អាចរកបានតាមរយៈ ៖http://bit.ly/1QDBfDm

[32] ដូចខាងលើ ។

*សវនាការកំបាំងមុខ*

៣៥. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្រោមច្បាប់អន្តរជាតិ និងច្បាប់ជាតិសម្រាប់កាត់ទោសជនត្រូវចោទដោយផ្ទាល់។

៣៦. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងថា ៖

*"ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"*[33]

មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា ៖

*"ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។"*[34]

មាត្រា ១៤ នៃ ក.ស.អ.ព.ន ដែលកម្ពុជាបានផ្តល់សច្ចាប័នក្នុងឆ្នាំ ១៩៩២ ហើយដែលអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់កម្ពុជា[35] ចែងថា ៖

*"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញ... ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន"*[36] ។

៣៧. សេចក្តីពន្យល់ទូទៅលេខ ១៣ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបញ្ជាក់បន្ថែមកាន់តែច្បាស់លើមាត្រា ១៤ នៃ ក.ស.អ.ព.ន ថា ៖

*"នៅពេលមានករណីពិសេសសម្រាប់បញ្ជាក់ហេតុផលពីសវនាការកំបាំងមុខត្រូវបានធ្វើឡើង នោះការប្រើប្រាស់សិទ្ធិការពារខ្លួនកាន់តែចាំបាច់"*[37]។

៣៨. មាត្រា ៣៦១ "សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ" និងមាត្រា ៣៦២ "សាលក្រមកំបាំងមុខ" នៃក្រមនីតិវិធីព្រហ្មទណ្ឌធ្វើឱ្យមានភាពធូរលុងចំពោះសវនាការកំបាំងមុខនៅប្រទេសកម្ពុជា។

មាត្រា ៣៦១ ចែងថា ៖

*"ប្រសិនបើជនជាប់ចោទមិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមដែលចាត់ទុកថាចំពោះមុខនេះ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទ។ ក្នុងករណីដែលជនជាប់ចោទ អវត្តមានបានបង្ហាញមូលហេតុអំពីការអវត្តមានរបស់ខ្លួន ហើយតុលាការក៏បានទទួលថាត្រឹមត្រូវ នោះតុលាការអាចលើករឿងទៅជំនុំជម្រះនៅសវនាការមួយក្រោយទៀត។"*

---

[33] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣៨ ។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣០០ ។

[35] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)។

[36] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤ ។

[37] សេចក្តីពន្យល់ទូទៅលេខ ១៣ របស់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (១៩៨៤) ។

មាត្រា ៣៦២ ចែងថា ៖

*"ប្រសិនបើជនជាប់ចោទមិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយនិងប្រសិនបើគ្មានភស្តុតាងបង្ហាញឱ្យឃើញថាសាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះ ឬបានដឹងអំពីដីកាកោះហៅនោះទេ សាលក្រមត្រូវប្រកាសដោយកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខជនជាប់ចោទ ត្រូវឱ្យដំណឹងដល់ជនជាប់ចោទនេះ ..."។*

***សេរីភាពខាងការបញ្ចេញមតិ និងការប្រមូលផ្តុំ***

៣៩. ជាងនេះទៅទៀត ដោយយោងទៅលើបរិបទនៃអង្គហេតុដែលករណីនេះបានកើតឡើងនេះ ការចោទប្រកាន់នេះធ្វើឡើងប្រឆាំងទៅលើបុគ្គលដែលពាក់ព័ន្ធនឹងបញ្ហាសិទ្ធិមនុស្ស សេរីភាពខាងការបញ្ចេញមតិ និងការប្រមូលផ្តុំរបស់ខ្លួន។ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌ និងការឃុំខ្លួនដើម្បីរារាំង និងការពិន័យបុគ្គលដែលចូលរួមក្នុងសកម្មភាពនៃការតវ៉ាដោយសន្តិវិធីស្របច្បាប់ ចាត់ទុកថាជាការរឹតត្បិតដោយមិនសមហេតុផលតាមផ្លូវច្បាប់ទៅលើសេរីភាពមូលដ្ឋានទាំងនេះ។

៤០. សេរីភាពខាងការបញ្ចេញមតិ និងការប្រមូលផ្តុំត្រូវបានការពារយ៉ាងរឹងមាំក្នុងច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ។ មាត្រា៤១ នៃរដ្ឋធម្មនុញ្ញចែងថា ៖

*"ប្រជាពលរដ្ឋមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។"*[38]

ដូចបានគូសបញ្ជាក់ក្នុងកថាខ័ណ្ឌ ៣១ ខាងលើ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិត្រូវអនុវត្តដោយផ្ទាល់នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាក្រោមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ។ មាត្រា១៩ និងមាត្រា ២១ នៃ ក.អ.ស.ព.ន ធានាដោយឡែកពីនេះនូវសេរីភាពខាងការបញ្ចេញមតិ និងការជួបប្រជុំដោយសន្តិវិធី។ នៅថ្នាក់តំបន់សិទ្ធិទាំងនេះត្រូវបានទទួលស្គាល់ក្នុងមាត្រា ២៣ និងមាត្រា២៤ នៃសេចក្តីប្រកាសសិទ្ធិមនុស្សអាស៊ាន។

## ៥ ការវិភាគជុំវិញការយកច្បាប់មកអនុវត្តចំពោះអង្គហេតុ

***បទគំរាមកំហែងថានឹងធ្វើឱ្យខូចខាតដែលភ្ជាប់នូវបញ្ជាអ្វីមួយ (មាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ)***

៤១. ជនជាប់ឃុំទាំងបីនាក់ដែលជាប់ចោទពីបទខាងលើនេះបានបដិសេធពីការទទួលខុសត្រូវគ្រប់បែបយ៉ាង។ ជាពិសេសទៅទៀតនោះ ពួកគេបដិសេធថាមិនបានគំរាមកំហែងបំផ្លិចបំផ្លាញសាឡង់បូមខ្សាច់ឬទ្រព្យសម្បត្តិផ្សេងទៀតនោះទេ។ ផ្ទុយទៅវិញ ពួកគេអះអាងថាសកម្មភាពរបស់ខ្លួនធ្វើឡើង

[38] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤១ ។

ដោយអហិង្សាហើយពួកគេបានព្យាយាមគ្រប់មធ្យោបាយដើម្បីឱ្យក្រុមមនុស្សដែលប្រមូលផ្តុំគ្នានោះស្ងប់ស្ងាត់។ តាមការអនុវត្តច្បាប់ទាក់ទិនទៅនឹងធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌ និងភស្តុតាងដាក់បន្ទុកសម្រាប់ការផ្តន្ទាទោសព្រហ្មទណ្ឌ ស្តែងឱ្យឃើញនូវចំណុចខ្សោយមួយចំនួនក្នុងការចោទប្រកាន់នេះ។

*ភាពមិនស៊ីសង្វាក់ និងភាពខ្សោយនៃភស្តុតាងដែលមាន*

៤២. ភស្តុតាងតែម្យ៉ាងគត់ដែលស្ថាប័នអយ្យការសំអាងសម្រាប់ការចោទប្រកាន់នេះ គឺយោងទៅលើចម្លើយរបស់សាក្សីមួយចំនួនដែលមានភាពមិនស៊ីសង្វាក់គ្នាខ្លាំង និងកង្វះខាតនៃភស្តុតាងដាក់បន្ទុកក្នុងបទល្មើសនេះដែលនាំឱ្យមានមន្ទិលទៅលើសក្ខីកម្ម។ សាក្សីមួយចំនួនតូចដែលអះអាងថាមានវត្តមានក្នុងអំឡុងពេលមានការតវ៉ាទាំងនោះ មិនបានផ្តល់ភស្តុតាងដាក់លាក់ណាមួយជុំវិញការគំរាមកំហែងពីជនត្រូវចោទឡើយ។ សាក្សីផ្សេងទៀតបានផ្តល់ចម្លើយទាំងពួកគេមិនមានវត្តមានក្នុងអំឡុងពេលតវ៉ា ដែលនាំឱ្យបាត់បង់ភាពជឿជាក់យ៉ាងខ្លាំងចំពោះសក្ខីកម្មបែបនេះ។

៤៣. មានចម្លើយរបស់សាក្សីមួយចំនួនលើកឡើងពីការតវ៉ានៅថ្ងៃទី២៦ និងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ និងនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥។ ទោះជាយ៉ាងណា នេះជាចំណុចសំខាន់ណាស់ដែលត្រូវកត់សម្គាល់ថាមានភស្តុតាងជាក់ស្តែងរឹងមាំបង្ហាញថា មិនមែនអ្នកជាប់ឃុំទាំងបីរូបនោះមានវត្តមានទាំងអស់គ្នាក្នុងការតវ៉ានៅថ្ងៃទី១២ ខែសីហា នោះឡើយ។ ចម្លើយរបស់ ទ្រី សុវិគា បញ្ជាក់ថាលោកមិនមានវត្តមាននៅក្នុងតំបន់អណ្តូងទឹកនៅថ្ងៃទី១២ ខែសីហាឡើយព្រោះលោកមានបញ្ហាសុខភាព ដូច្នេះលោកត្រូវធ្វើដំណើរទៅខេត្តកោះកុង។ ដូច្នេះនេះជាចំណុចសំខាន់បញ្ជាក់ច្បាស់ថាភស្តុតាងជាក់ស្តែងណាមួយជាប់ទាក់ទងទៅនឹងព្រឹត្តិការណ៍ថ្ងៃទី១២ ខែសីហា មិនអាចត្រូវបានប្រើដើម្បីគាំទ្រដល់ការចោទប្រកាន់ទៅលើយ៉ាងហោចណាស់ជនជាប់ចោទម្នាក់ក្នុងចំណោមជនជាប់ឃុំ។ ជាងនេះទៅទៀត ភស្តុតាងនោះត្រូវតែជាប់ពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅចន្លោះថ្ងៃទី២៦ និងថ្ងៃទី២៨ ខែកក្កដា ទោះជាយ៉ាងណា ក៏គួរកត់សម្គាល់ផងដែរថានៅថ្ងៃទី២៨ ខែកក្កដា ជនជាប់ចោទម្នាក់ទៀត គឺ ស៊ឹម សំណាង មិនមានវត្តមានក្នុងព្រឹត្តិការណ៍នោះទេ។ នៅព្រឹកថ្ងៃទី២៨ ខែកក្កដា ស៊ឹម សំណាង បានចាកចេញពីអណ្តូងទឹកទៅកាន់ក្រុងកោះកុង នេះមានន័យថានៅថ្ងៃទី២៨ ខែកក្កដា មានតែជនត្រូវចោទពីរនាក់ប៉ុណ្ណោះដែលមានវត្តមាននៅកន្លែងកើតហេតុ។ អវត្តមានរបស់ ទ្រី សុវិគា និង ស៊ឹម សំណាង អាចបញ្ជាក់បានតាមរយៈសារនៅលើទំព័រហ្វេសប៊ុក រវាងពួកគេជាមួយនឹងលោក អាឡិចហ្សង់ដ្រូ ហ្គនហ្សាឡេហ្ស ដាវីដសុន។[39]

៤៤. សាក្សីពីរនាក់ថ្លែងថាពួកគេមិនបានចាំកាលបរិច្ឆេទនៃព្រឹត្តិការណ៍ដែលកើតឡើងតាមការអះអាងរបស់ខ្លួនឡើយ ហើយលើកឡើងផ្តោតតែទៅលើកាលបរិច្ឆេទ (ថ្ងៃទី១២ ខែសីហា និងទី២៨ ខែកក្កដា) ដែលមិនមែនគ្រប់ជនត្រូវចោទទាំងបីនាក់ មានវត្តមាននៅថ្ងៃនោះទាំងអស់គ្នាទេ។

---

[39] សូមមើលឧបសម្ព័ន្ធទី ១ រូបភាពពីអេក្រង់លេខ ១ និងលេខ ២។

*កង្វះខាតភស្តុតាងជាក់លាក់ដែលថាជនត្រូវចោទបានគំរាមកំហែងថានឹងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ*

៤៥. បើទោះបីជាការទុកចិត្តទៅលើភស្តុតាងរបស់សាក្សីត្រូវបានទទួលយកដើម្បីជាប្រយោជន៍សម្រាប់ការដេញដោលក៏ដោយ ពុំមានភស្តុតាងច្បាស់លាស់ក្នុងសេចក្តីថ្លែងទាំងនោះដែលថាជនត្រូវចោទដែលកំពុងជាប់ឃុំទាំងនោះបានប្រព្រឹត្តបទល្មើសឡើយ យោងតាមលក្ខខណ្ឌជាក់លាក់នៃបទល្មើសបានកំណត់ដោយច្បាប់ និងផ្អែកទៅលើភស្តុតាងជាក់បន្ទុកដែលតម្រូវដោយច្បាប់សម្រាប់ការផ្តន្ទាទោសពីបទល្មើសព្រហ្មទណ្ឌ។ ដូចដែលបានបញ្ជាក់ខាងលើ ចំពោះជនត្រូវចោទដែលត្រូវផ្តន្ទាទោសពីបទល្មើសនេះលុះត្រាតែស្ថិតនៅក្នុងលក្ខខណ្ឌ ៖ (១) ពួកគេបានធ្វើការគំរាមកំហែងជាក់ស្តែងច្បាស់លាស់ និងជាក់លាក់ (២) ការគំរាមកំហែងត្រូវធ្វើឡើងដោយបញ្ជាក់ច្បាស់ថាជនជាប់ចោទនឹងបង្កការខូចខាតដល់ទ្រព្យសម្បត្តិ និង (៣) ការគំរាមកំហែងត្រូវតែភ្ជាប់មកជាមួយនូវការព្រមានជាក់លាក់ និងច្បាស់លាស់ដល់អ្នកទទួលបញ្ជាឱ្យធ្វើ ឬក៏មិនធ្វើសកម្មភាពជាក់លាក់ណាមួយ។ ក្នុងករណីនេះ ជនត្រូវចោទរងការចោទប្រកាន់ពីបទថាបានគំរាមកំហែង (ថានឹងដុតសាឡង់បូមខ្សាច់) ដែលភ្ជាប់នូវបញ្ជា (បញ្ឈប់ការបូមខ្សាច់ និងបង្គាប់ឱ្យចាកចេញពីច្រាំងព្រែក)។ ដើម្បីកាត់ទោសជនត្រូវចោទពីបទល្មើសនេះ លុះត្រាតែគ្មានវិមតិសង្ស័យណាមួយ ដែលថាជនត្រូវចោទម្នាក់ក្នុងចំណោមជនត្រូវចោទទាំងបីបានធ្វើការគំរាមកំហែងឱ្យខូចខាតដល់សាឡង់បូមខ្សាច់ ហើយថាបានបង្គាប់បញ្ជាឱ្យបុគ្គលិកសាឡង់បូមខ្សាច់ចាកចេញពីច្រាំងព្រែក។ មានការលើកឡើងជាទូទៅថា ជនមិនស្គាល់អត្តសញ្ញាណមួយចំនួនមានវត្តមាននៅក្នុងក្រុមធំដែលអាចជាអ្នកធ្វើការគំរាមកំហែងនេះ ហើយករណីនេះមិនសមហេតុផលទាល់តែសោះដែលឱ្យជនជាប់ឃុំទាំងបីនាក់នោះត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។

៤៦. ចំណុចមួយដែលបានលើកឡើងតាមរយៈការលើកឡើងរបស់សាក្សីស្ទើតែគ្រប់គ្នានោះគឺថា នៅចន្លោះថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដា មនុស្សមួយក្រុមដែលមានប្រជាសហគមន៍មូលដ្ឋាន និងសកម្មជនអង្គការមាតាធម្មជាតិមួយចំនួនតូចបានធ្វើដំណើរទៅកាន់សាឡង់បូមខ្សាច់ដោយប្រើទូកតូចមួយគ្រឿង និងបានប្រាប់ឱ្យកម្មករបញ្ឈប់ការបូមខ្សាច់ និងចាកចេញពីតំបន់នោះ។ ការលើកឡើងរបស់សាក្សីស្ទើតែទាំងអស់សុទ្ធតែគាំទ្រចម្លើយនេះ។ ប៉ុន្តែមានសាក្សីតែពីរបីនាក់ប៉ុណ្ណោះលើកឡើងពីការប្រើភាសាប្រមាថ ឬការគំរាមកំហែងពីសមាជិកក្រុម ហើយគ្មានសាក្សីណាម្នាក់លើកឡើងថាភាសាប្រមាថនេះត្រូវបានអ្នកជាប់ឃុំទាំងនោះប្រើឡើយ។[40] នេះជាចំណុចមួយក្នុងចំណោមចំណុចជាច្រើនដែលស៊ីសង្វាក់គ្នាទាំងស្រុងទៅនឹងភស្តុតាងដែលមាន។ ការលើកឡើងរបស់សាក្សីម្នាក់ដែលជាមន្រ្តីថ្នាក់ស្រុកបានបំភ្លឺជុំវិញព្រឹត្តិការណ៍ទូទៅនៅថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដា ហើយគាត់ពុំបានអះអាងថាមានការគំរាមកំហែង ឬភាសាប្រមាថអ្វីឡើយ។ សាក្សីទីពីរក៏គ្រាន់តែបញ្ជាក់ពីព្រឹត្តិការណ៍

[40] ការដាក់ស្នើឱ្យស៊ើបសួរពាក់ព័ន្ធនឹងថ្ងៃទី២៦-២៨ ខែកក្កដា សេចក្តីថ្លែងរបស់សាក្សី និងសេចក្តីថ្លែងដោយ សាន់ ម៉ាឡា ស៊ីម សំណាង និងទ្រី សុភិតា។

នៅថ្ងៃទីថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដា និងគ្មានអំណះអំណាងអ្វីថាមានការគំរាមកំហែង ឬភាសាប្រមាថដូចគ្នាដែរ។

៤៧. ទោះបីជាសេចក្តីថ្លែងរបស់សាក្សីបង្ហាញថាមានការគំរាមកំហែងធ្វើឱ្យខូចខាតសាឡង់បូមខ្សាច់បង្កឡើងដោយមនុស្សមួយចំនួននៅក្នុងក្រុមនោះ ភស្តុតាងនេះមានលក្ខណៈទូទៅពេក ហើយសំខាន់ជាងនេះទៅទៀត **ក្នុងចំណោមភស្តុតាងទាំងនោះគ្មានភស្តុតាងណាអះអាងថាអ្នកដែលកំពុងជាប់ឃុំទាំងនោះបានគំរាមកំហែងធ្វើឱ្យខូចសាឡង់បូមខ្សាច់ឡើយ ប៉ុន្តែបានសំដៅទៅលើក្រុមមនុស្សមានគ្នាច្រើននាក់ទៅវិញ។** គ្មានភស្តុតាងណាមួយផ្តល់មូលដ្ឋានជាក់លាក់ដើម្បីបង្ហាញថាជនជាប់ឃុំទាំងនោះរួចផុតពីវិមតិសង្ស័យដែលច្បាប់កំណត់ឡើយ។ ដូចបានកត់សម្គាល់ខាងលើ នៅចន្លោះថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដា មានព្រឹត្តិការណ៍តវ៉ាជាច្រើនបានកើតឡើងនៅលើទីតាំងបូមខ្សាច់សំខាន់ៗមួយចំនួន ដោយមានការចូលរួមពីក្រុមមនុស្សជាច្រើនរហូតដល់ទៅ ១៥០ នាក់ ហើយពួកគេបានចែកគ្នាជាក្រុមតូចៗជិះទូកនេសាទមានគ្នាពី ១០ ទៅ ១៥ នាក់ក្នុងមួយទូក។ ដូច្នេះ ការលើកឡើងរបស់សាក្សីដែលជាបុគ្គលិកក្រុមហ៊ុន ដាយរិក អាកសេស (Direct Access) ដែលបានអះអាងថាក្រុមអ្នកតវ៉ាបានប្រើភាសាប្រមាថ តែសាក្សីផ្សេងទៀតអះអាងថា *"មនុស្សមួយចំនួន"* ក្នុងក្រុមដែលមានគ្នា ១៥០ នាក់ បានគំរាមកំហែងដុតសាឡង់បូមខ្សាច់នោះ មិនអាចជាមូលដ្ឋានសម្រាប់ធ្វើការចោទប្រកាន់ទៅលើសកម្មជនជាប់ឃុំ ឬក៏លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន បានឡើយ។ ករណីនេះមិនអាចកំណត់តាមរយៈការលើកឡើង ដែលមិនច្បាស់លាស់ទាំងនេះបានទេព្រោះមិនដឹងថានរណាជាអ្នកបានគំរាមកំហែង ហើយគំរាមយ៉ាងដូចម្តេចនោះទេ។

៤៨. សាក្សីមួយរូបដែលបម្រើការនៅមន្ទីររ៉ែនិងថាមពលក្នុងខេត្តកោះកុងបានអះអាងស្រដៀងគ្នាទៅនឹងសាក្សីផ្សេងទៀតដែរថា ក្រុមអ្នកតវ៉ាបានគំរាមកំហែង និងប្រើភាសាប្រមាថ។ សាក្សីដដែលអះអាងថានគរបាលមិនអាចធ្វើអន្តរាគមន៍បញ្ឈប់អ្នកតវ៉ាបានទេ ទោះជាមានវត្តមាននគរបាលច្រើននាក់ក្នុងចំណោមអ្នកតវ៉ាដោយសន្តិវិធីក៏ដោយ ប៉ុន្តែពួកគេគ្រាន់តែជិះទូកក្រឡឹងជុំវិញសាឡង់ខ្សាច់និងថតរូបភាពប៉ុណ្ណោះ។ ការដឹងនូវព្រឹត្តិការណ៍របស់សាក្សីរូបនេះគឺគួរឱ្យសង្ស័យបំផុត ព្រោះគាត់មិនមានវត្តមាននៅកន្លែងកើតហេតុនោះទេ។

៤៩. បញ្ហាភាសាទំនាក់ទំនងរវាងជនត្រូវចោទដែលកំពុងជាប់ឃុំ ដែលនិយាយតែភាសាខ្មែរ និងកម្មករជនជាតិវៀតណាមនៅលើសាឡង់បូមខ្សាច់ដែលមិនអាចនិយាយភាសាខ្មែរនោះ កាន់តែធ្វើឱ្យងឿងឆ្ងល់យ៉ាងខ្លាំងថាតើលើលទ្ធភាពរបស់កម្មករបូមខ្សាច់ក្នុងការផ្តល់ភស្តុតាងគួរឱ្យជឿទុកចិត្តបានដែរឬយ៉ាងណាចំពោះខ្លឹមសារនៃពាក្យសម្តីដែលបានពោលឡើងដោយអ្នកជាប់ឃុំទាំងនោះហើយថាតើជាការគំរាមកំហែង ឬជាការបង្គាប់បញ្ជា។

៥០. ជាងនេះទៅទៀត អយ្យការខ្លួនឯងក៏មិនបានអះអាងថាមានការគំរាមកំហែងកើតឡើងនៅចន្លោះថ្ងៃទី២៦ ដល់ថ្ងៃទី២៨ ខែកក្កដានោះទេ ប៉ុន្តែបែរជាអះអាងថាមានការគំរាមកំហែងកើតឡើងនៅថ្ងៃទី

១២ ខែសីហាទៅវិញ។ **មិនមែនគ្រប់ជនត្រូវចោទទាំងអស់មានវត្តមានទាំងអស់គ្នានៅថ្ងៃ១២ ខែសីហា នោះឡើយ។** ម្យ៉ាងទៀត ការចោទប្រកាន់របស់អយ្យការមិនច្បាស់លាស់អំពីប្រភេទនៃការគំរាមកំហែង បុគ្គលដែលបានគំរាមកំហែងពិតប្រាកដ ឬក៏ពេលវេលាជាក់លាក់ដែលពួកគេបានគំរាមកំហែងនោះ ឡើយ។

៥១. ដូច្នេះ ក្នុងករណីនេះ មានការខ្វះខាតទាំងស្រុងនូវព័ត៌មានច្បាស់លាស់ និងព័ត៌មានលម្អិតពិត ប្រាកដ ដែលអាចផ្តល់ជាមូលដ្ឋានសម្រាប់ការកាត់ទោសតាមមាត្រា ៤២៤ នៃក្រមព្រហ្មទណ្ឌ ដែល តម្រូវជាពិសេសឱ្យផុតពីវិមតិសង្ស័យទៅលើពិរុទ្ធភាពនៃជនត្រូវចោទ។ គ្មានការលើកឡើងរបស់សាក្សី ណាមួយបង្ហាញពីហេតុការណ៍លំអិតថាជនជាប់ឃុំពិតជាបានគំរាមកំហែងធ្វើឱ្យខូចខាតសាឡង់បូម ខ្សាច់នោះឡើយ។

៥២. មានភស្តុតាងបញ្ជាក់ថាកម្មករនៅលើសាឡង់ចង់ប្រឌិតរឿងនេះឡើងបង្ហាញឱ្យឃើញថាអ្នកតវ៉ា បានធ្វើសកម្មភាពខុសច្បាប់ ហើយកិច្ចការនេះអាចមានការគាំទ្រពីអាជ្ញាធរផងដែរ។ រាល់ភស្តុតាង ដែលសាក្សីបានផ្តល់ជូនដោយភ្ជាប់ក្រុមទាំងនេះគួរត្រូវយកមកពិចារណាឲ្យបានប្រុងប្រយ័ត្ន។ ហេតុ ការណ៍មួយដែលសកម្មជនអង្គការមាតាធម្មជាតិថតរូបភាពបាន ដោយរួមមានរូបភាពរបស់កម្មករជន ជាតិវៀតណាមម្នាក់នៅលើសាឡង់កំពុងចងខ្លួនឯងនឹងខ្សែពួរក្នុងបំណងទំលាក់កំហុសនេះទៅលើ ក្រុមអ្នកតវ៉ា។ នគរបាលក៏បានថតវីដេអូហេតុការណ៍នោះផងដែរ ប៉ុន្តែមិនបានធ្វើអន្តរាគមន៍អ្វីទាំងអ ស់។ ជាងនេះទៅទៀត នៅថ្ងៃទី៣០ ខែកក្កដា ការតវ៉ាមួយត្រូវបានបញ្ឈប់ទៅវិញនៅពេលដែលសកម្ម ជនអង្គការមាតាធម្មជាតិទទួលបានព័ត៌មានថា ក្នុងចំណោមអ្នកភូមិមួយក្រុមដែលមកចូលរួមដែរនោះ មានទាហានស្លៀកពាក់ស៊ីវិលបង្កប់មកចូលរួមជាមួយអ្នកភូមិដើម្បីរំខានដល់ការតវ៉ា និងបង្កការប៉ះ ទង្គិចជាមួយអាជ្ញាធរ។ [41]

*ភស្តុតាងដោះបន្ទុកដែលបញ្ជាក់ថាសកម្មភាពរបស់ជនជាប់ឃុំពិតជាអហិង្សា ហើយពួកគេព្យាយាមធ្វើឱ្យស្ថាន ការណ៍ស្ងប់ស្ងាត់*

៥៣. មិនត្រឹមតែគ្មានភស្តុតាងជាក់លាក់ណាមួយដែលថាជនជាប់ចោទពិតជាបានធ្វើការគំរាមកំហែង នោះទេ តែផ្ទុយទៅវិញមានភស្តុតាងដោះបន្ទុកដែលគួរឱ្យពិចារណា ថាពួកគេបានខិតខំព្យាយាមធ្វើឱ្យ ស្ថានការណ៍ស្ងប់ស្ងាត់និងអហិង្សា។ ភស្តុតាងដែលមានស្រាប់បានង្ហាញថាជនជាប់ឃុំទាំងបីនាក់បាន ធ្វើសកម្មភាពអហិង្សាផ្ទាល់។ លើសពីនេះទៅទៀត ជនជាប់ឃុំទាំងនោះស្ថិតនៅក្នុងចំណោមប្រជា សហគមន៍មូលដ្ឋានជាច្រើនណែនណាន់តាន់តាប់មានចំនួនរហូតដល់ទៅ ១៥០ នាក់ ដែលក្រុមប្រជា ពលរដ្ឋទាំងនោះមិនអាចគ្រប់គ្រងអារម្មណ៍ខឹងសម្បារបាន ដោយសារតែ ការប្រកបរបរចិញ្ចឹមជីវិត និងបរិស្ថានរបស់ពួកគាត់រងផលប៉ះពាល់យ៉ាងខ្លាំងដោយសារតែការបូមខ្សាច់នោះ។

---

[41] អូន ភាព "ការតវ៉ាប្រឆាំងការបូមខ្សាច់នៅខេត្តកោះកុងត្រូវបញ្ឈប់" ខេមបូឌា ដេលី ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥។

៥៤. អហិង្សាមិនមែនត្រឹមតែជាគោលការណ៍មូលដ្ឋានមួយរបស់អង្គការមាតាធម្មជាតិប៉ុណ្ណោះទេ[42] ប៉ុន្តែថែមទាំងមានភស្តុតាងបញ្ជាក់តាមរយៈសារឆ្លងឆ្លើយនៅលើបណ្តាញហ្វេសប៊ុករវាងសកម្មជនអង្គការមាតាធម្មជាតិទៀតផង ដែលបញ្ជាក់ និងឯកភាពទៅលើសារៈសំខាន់នៃអហិង្សា។ ការឆ្លងឆ្លើយគ្នាតាមរយៈហ្វេសប៊ុកនេះរួមមាន សាន់ ម៉ាឡា និងស៊ឹម សំណាង ដែលបានព្រមព្រៀងគ្នាយ៉ាងច្បាស់ថារក្សាសកម្មភាពទាំងអស់ដោយសន្តិវិធី។[43] សាក្សីមួយចំនួនដែលមានវត្តមាននៅកន្លែងតវ៉ានោះបានថ្លែងយ៉ាងច្បាស់ថា សកម្មជនអង្គការមាតាធម្មជាតិបានធ្វើសកម្មភាពដើម្បីឱ្យការប្រមូលផ្តុំសមាជិកសហគមន៍ស្ងប់ស្ងាត់ និងស្នើឱ្យពួកគេតវ៉ាដោយអហិង្សា។ ម.ស.ម.ក បានសម្ភាសសាក្សីដែលមានវត្តមាននៅកន្លែងកើតហេតុ ហើយពួកគេម្នាក់ៗថ្លែងយ៉ាងច្បាស់ថាជនជាប់ឃុំទាំងបីនាក់បានធ្វើសកម្មភាពដើម្បីឱ្យស្ថានការណ៍ស្ងប់ស្ងាត់ និងស្នើឱ្យប្រជាសហគមន៍ដែលមក ប្រមូលផ្តុំគ្នាទាំងនោះតវ៉ាដោយអហិង្សា។

៥៥. ជនជាប់ឃុំទាំងបីនាក់និយាយម្តងហើយម្តងទៀតថាសកម្មភាពរបស់ពួកគេគឺធ្វើឡើងដោយសន្តិវិធីទាំងស្រុង។ ពួកគេទាំងអស់គ្នានិយាយថា ពួកគេមិនបានប្រើភាសាប្រមាថ ឬក៏បានគំរាមកំហែងធ្វើឱ្យខូចខាតសាឡង់បូមខ្សាច់ ឬសម្ភារៈអ្វីឡើយ ហើយក៏មិនបានធ្វើឱ្យសាឡង់ខូចខាតដោយមធ្យោបាយណាមួយឡើយពេលពួកគេឡើងទៅលើសាឡង់នោះ។ ទ្រី សុវិគា បញ្ជាក់ថាបានបញ្ចុះបញ្ចូលឱ្យអ្នកតវ៉ាដែលមកពីសហគមន៍ត្រឡប់ទៅផ្ទះវិញនៅរៀងរាល់ល្ងាច ហើយគាត់ព្យាយាមធ្វើឱ្យស្ថានការណ៍ធូរស្រាលនៅពេលសភាពការណ៍តានតឹង។ នៅក្នុងសេចក្តីថ្លែងរបស់ខ្លួន ស៊ឹម សំណាង អះអាងថាគាត់មិនបានលឺអ្នកតវ៉ាណាម្នាក់គំរាមកំហែងថានឹងធ្វើឱ្យខូចខាត ឬដុតសាឡង់បូមខ្សាច់នោះឡើយ។

៥៦. នៅក្នុងវីដេអូដែលថតដោយលោក សាន់ ម៉ាឡា នៅថ្ងៃទី១២ ខែសីហា[44] គាត់ពន្យល់ថាក្រុមហ៊ុនបូមខ្សាច់បានជួលអ្នកភូមិមួយក្រុមមកពីស្រុកបុទុមសាគរដើម្បីបង្កហិង្សា និងតទល់គ្នា **ប៉ុន្តែសកម្មជនទាំងនោះបានព្យាយាមអស់ពីលទ្ធភាពដើម្បីបញ្ចៀសមិនឱ្យមានអំពើហិង្សាកើតឡើង ហើយបានព្យាយាមគ្រប់គ្រងស្ថានការណ៍ និងធ្វើឱ្យសភាពការណ៍ស្ងប់ស្ងាត់។** វីដេអូនោះបង្ហាញថារូបភាពអ្នកភូមិកំពុងអង្គុយយ៉ាងស្ងប់ស្ងាត់នៅលើទូកមួយពីខាងក្រោយលោក សាន់ ម៉ាឡា។ តាមរយៈសារជាសំឡេងមួយពី ទ្រី សុវិគា ដែលបានបញ្ជូនព័ត៌មានបន្តដែលប្រមូលបានពី សាន់ ម៉ាឡា នៅថ្ងៃដដែលនោះ បានលើកឡើងថាអ្នកភូមិត្រូវបានគេជួលដើម្បីបញ្ឈប់សកម្មភាពរបស់អ្នកតវ៉ា ប៉ុន្តែសកម្មជនអង្គការមាតាធម្មជាតិបានធ្វើអន្តរាគមន៍ដើម្បីរក្សាភាពស្ងប់ស្ងាត់ និងទប់ស្កាត់អំពើហិង្សា។[45]

### *ការទទួលខុសត្រូវរបស់អ្នកសមគំនិត (មាត្រា ២៩ នៃក្រមព្រហ្មទណ្ឌ)*

---

[42] មើលនៅផ្នែកទី ១។

[43] មើលឧបសម្ព័ន្ធទី ១ រូបថតទី ៣ និងទី ៤។

[44] មើលឧបសម្ព័ន្ធទី ២ សម្រាប់វីដេអូ និងប្រតិចារឹកជាភាសាអង់គ្លេស។

[45] មើលឧបសម្ព័ន្ធទី ៣ សម្រាប់សំឡេង និងប្រតិចារឹកជាភាសាអង់គ្លេស។

៥៧. ជាដំបូង ក្នុងករណីមិនមានសកម្មភាពព្រហ្មទណ្ឌ ឬបានប៉ុនប៉ងធ្វើសកម្មភាពព្រហ្មទណ្ឌ ការទទួលខុសត្រូវរបស់អ្នកសមគំនិតមិនអាចកើតឡើងបានឡើយ។ ដូចបានលើកឡើងខាងលើ ការចោទប្រកាន់ពីបទព្រហ្មទណ្ឌទៅលើអ្នកជាប់ឃុំទាំងបីនាក់នោះមានការចន្លោះប្រហោងជាខ្លាំង។

៥៨. គ្រប់ករណីទាំងអស់ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន បានបដិសេធដាច់ខាតចំពោះការទទួលខុសត្រូវថាជាអ្នកសមគំនិតទាក់ទងនឹងបទចោទប្រឆាំងនឹងជនត្រូវចោទបីរូបផ្សេងទៀត។ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស អះអាងថាលោកមិនបានធ្វើសកម្មភាពណាមួយដើម្បីសម្រួលឱ្យមានការប្រព្រឹត្តដូចការចោទប្រកាន់នោះទេ តែផ្ទុយទៅវិញលោកបានផ្ញើសារទៅកាន់សកម្មជនដែលចូលរួមការតវ៉ាដោយលើកឡើងពីសារៈសំខាន់នៃការប្រកាន់យកសកម្មភាពសន្តិវិធី។ ការអនុវត្តច្បាប់ទាក់ទងនឹងលក្ខខណ្ឌតម្រូវច្បាស់លាស់សម្រាប់ការទទួលខុសត្រូវក្នុងបទល្មើសសមគំនិត និងបទដ្ឋាននៃភស្តុតាងសម្រាប់ការផ្តន្ទាទោសព្រហ្មទណ្ឌ ចំពោះលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ទទួលខុសត្រូវពីបទសមគំនិត គឺជារឿងដែលមិនអាចទទួលយកបាន។

*ការទទួលខុសត្រូវរបស់អ្នកសមគំនិតត្រូវតែផ្អែកលើសកម្មភាពជាក់ស្តែង*

៥៩. ទីមួយ ច្បាប់បានចែងយ៉ាងច្បាស់ថាការទទួលខុសត្រូវរបស់អ្នកសមគំនិតត្រូវតែជាប់ទាក់ទងទៅនឹងសកម្មភាពជាក់ស្តែងប្រព្រឹត្តដោយជនជាប់ចោទ។ នេះអាចជា "ការបង្កហេតុ" ដែលទទួលបានការគាំទ្រជាបន្តបន្ទាប់តាមរយៈការគំរាមកំហែង ឬរង្វាន់លើកទឹកចិត្ត ឬអាចជា "ការផ្តើមគំនិត" ឬជាការណែនាំយ៉ាងជាក់ច្បាស់ឱ្យប្រព្រឹត្តបទល្មើសជាក់ស្តែងណាមួយ ឬអាចជាការជួយ ឬគាំទ្រផ្ទាល់ដែលជម្រុញឱ្យមានចារីប្រព្រឹត្តបទល្មើស។ ភស្តុតាងដែលមានស្រាប់នេះមិនបានបង្ហាញស កម្មភាពបែបនេះទាល់តែសោះ។ តួនាទីទូទៅរបស់លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ជាអ្នកដឹកនាំដ៏សកម្មរបស់អង្គការមាតាធម្មជាតិ គឺពុំមានហេតុផលគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវជាអ្នកសមគំនិតលើការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ណាមួយនោះឡើយ។

៦០. ការចោទប្រកាន់នាពេលនេះហាក់បង្ហាញថាលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស អាចជាអ្នកសមគំនិតដោយសារតែលោកជានាយកអង្គការមាតាធម្មជាតិ និងជាអ្នកចាត់ចែងការឧបត្ថម្ភដល់សកម្មជនអង្គការមាតាធម្មជាតិ។ ការរៀបចំបែបនេះអាចចាត់ថាជា "ការបង្កហេតុ" ជុំវិញករណីនេះដោយទទួលនូវការគំរាមកំហែង ឬទទួលបានរង្វាន់លើកទឹកចិត្ត ដែលនាំឱ្យចារីបន្តសកម្មភាពព្រហ្មទណ្ឌ។ ម្យ៉ាងវិញទៀត អង្គការមាតាធម្មជាតិចាំបាច់ត្រូវបញ្ជាក់ពីគោលបំណងក្នុងការប្រព្រឹត្តបទល្មើសដើម្បីផ្សារភ្ជាប់ករណីនេះ។ ផ្ទុយទៅវិញ អហិង្សាគឺជាមូលដ្ឋានគ្រឹះរបស់អង្គការមាតាធម្មជាតិ ហើយជាលទ្ធផលអហិង្សាគឺត្រូវបានអនុវត្តនៅគ្រប់ដំណាក់កាលនៃការតស៊ូមតិរបស់អង្គការមាតាធម្មជាតិ។

៦១. ម្យ៉ាងវិញទៀត ករណីនេះអាចត្រូវបានអះអាងថាលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បានផ្តល់ការណែនាំជាក់លាក់ដល់ជនជាប់ឃុំឱ្យគំរាមកំហែងធ្វើឱ្យខូចខាតសាឡង់បូមខ្សាច់។ ទោះជាយ៉ាងណាគ្មានភស្តុតាងណាមួយបង្ហាញទាល់តែសោះ និងគ្មានការលើកឡើងបែបនេះនៅក្នុងភស្តុតាងដែល

មានស្រាប់ឡើយ។ ដូចគ្នាដែរទៅនឹងករណីលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ពុំមានភស្តុតាងគ្រប់គ្រាន់បង្ហាញថា អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ជួយដោយផ្ទាល់ ឬជួយសម្រួលដល់ជនជាប់ឃុំទាំងនោះ ដើម្បីឱ្យពួកគេអាចប្រព្រឹត្តបទល្មើសបាននោះទេ។ ផ្ទុយទៅវិញ សារឆ្លើយឆ្លងតាមរយៈទំព័រហ្វេសប៊ុកនៅពេលតវ៉ាគឺជាភស្តុតាងបញ្ជាក់យ៉ាងច្បាស់ថាលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បានបញ្ជាក់ពីសារៈសំខាន់នៃគោលការណ៍អហិង្សា ជាការឆ្លើយតបទៅនឹងការលើកឡើងរបស់សហការីម្នាក់ដែលកំពុងតែសម្រួលការតវ៉ានោះឱ្យប្រព្រឹត្តទៅដោយសន្តិវិធី ដោយមានការក្រើនរំលឹកពីគោលការណ៍ដែលជាមុខងារសំខាន់ក្នុងនាមជាសកម្មជន។[46]

***អ្នកសមគំនិតត្រូវមានចេតនាក្នុងការសម្របសម្រួលឱ្យមានបទល្មើស***

៦២. ទីពីរ អ្នកសមគំនិតត្រូវតែបានធ្វើសកម្មភាពដោយចេតនាដើម្បីជួយដល់ចារីក្នុងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយដឹងច្បាស់ជាមុនថាពួកគេអាចធ្វើដូច្នេះមែន។ នេះជាចំណុចសំខាន់ដែលអ្នកសមគំនិត "ដឹងជាមុន" ថា ពួកគេកំពុងជួយសម្រួលឱ្យមានបទល្មើសព្រហ្មទណ្ឌ ដែលពុំមែនជាអំពើស្របច្បាប់។ គ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថាលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បានធ្វើសកម្មភាពដោយចេតនាពិតប្រាកដក្នុងការជួយសម្រួលឱ្យមានការប្រព្រឹត្តបទល្មើសឡើយ។ ផ្ទុយទៅវិញ មានភស្តុតាងដែលអាចបញ្ជាក់បានថាលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បានព្យាយាមច្រើនក្នុងការធានាឱ្យយុទ្ធនាការអង្គការមាតាធម្មជាតិប្រព្រឹត្តទៅដោយអហិង្សាគ្រប់ពេលវេលា ដូច្នេះគ្មានសកម្មជនណាម្នាក់នៃអង្គការមាតាធម្មជាតិអាចត្រូវទទួលខុសត្រូវចំពោះការរំលោភច្បាប់នោះទេ។ ទោះបីជាលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ស្ថិតនៅក្រៅប្រទេស ក៏លោកមានតួនាទីសំខាន់ក្នុងការការបង្ហាញពីសារៈសំខាន់នៃការតវ៉ាដោយត្រឹមត្រូវតាមច្បាប់ និងអហិង្សាតាមរយៈការប្រាស្រ័យទាក់ទងគ្នាតាមបណ្តាញសង្គមជាមួយនឹងសកម្មជន។ រូបភាពថតចេញពីហ្វេសប៊ុករបស់លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បង្ហាញឱ្យឃើញពីសារឆ្លើយឆ្លងដែលដាក់ចំណងជើង "ការបូមខ្សាច់" ហើយសារទាំងនោះសរសេរនៅមុនម៉ោង ៣ រសៀល ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥។[47] **តាមរយៈសារទៅកាន់ជនជាប់ឃុំទាំងនោះ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បញ្ជាក់យ៉ាងច្បាស់ថាការរក្សាបាតុកម្មអហិង្សាគឺជាភារកិច្ចសំខាន់របស់សកម្មជនអង្គការមាតាធម្មជាតិ។** សកម្មជនម្នាក់មានវត្តមាននៅក្នុងការតវ៉ាបានឆ្លើយតបទៅកាន់លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដោយអះអាងថា "*ឥឡូវខ្ញុំកំពុងព្យាយាមរក្សាអហិង្សា*"។[48] ភស្តុតាងនេះបញ្ជាក់យ៉ាងច្បាស់ថាចេតនារបស់ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ក្នុងរឿងនេះគឺត្រឹមតែធានាឱ្យមានការរក្សាអហិង្សាប៉ុណ្ណោះ។

***ត្រូវតែជាបទល្មើសព្រហ្មទណ្ឌជាក់ស្តែង***

[46] មើលរូបភាពទី ៣ ក្នុងឧបសម្ព័ន្ធទី ១ ។

[47] មើលរូបភាពទី ៤ ក្នុងឧបសម្ព័ន្ធទី ១។

[48] សារនៅលើទំព័រហ្វេសប៊ុកបញ្ជាក់ពីអហិង្សា។

៦៣. ប្រាកដណាស់ បើមិនអាចបង្ហាញថាមានបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តដោយជនជាប់ឃុំទេ នោះក៏ពុំអាចតម្រូវឱ្យលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ទទួលខុសត្រូវជាអ្នកសមគំនិតផងដែរ។ ដូចបានគូសបញ្ជាក់យ៉ាងច្បាស់ខាងលើ គ្មានភស្តុតាងច្បាប់ដែលគាំទ្រដល់ការកាត់ទោសជនជាប់ឃុំទាំងបីនាក់នោះឡើយ។

# ៦ បញ្ហាច្បាប់ដែលពាក់ព័ន្ធ

៦៤. ក្រៅពីបទចោទទៅលើជនត្រូវចោទទាំងបួននាក់ មានបញ្ហាមួយចំនួនកើតឡើងពាក់ព័ន្ធនឹងផ្លូវច្បាប់ជាពិសេសនោះគឺនិត្យានុកូលភាពនៃការឃុំខ្លួនបណ្តោះអាសន្នអ្នកទាំងបីនាក់រយៈពេលយូរ និងផលប៉ះពាល់លើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដោយសារការនិរទេសខ្លួនលោកចេញពីកម្ពុជា។

*ការឃុំខ្លួនបណ្តោះអាសន្នរយៈពេលយូរ*

៦៥. បន្ទាប់ពីចាប់ខ្លួន និងចោទប្រកាន់នៅក្នុងខេត្តកោះកុងនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ រួចមក សាន់ ម៉ាឡា ទ្រី សុវិកា និង ស៊ីម សំណាង ត្រូវបានបន្តឃុំខ្លួនបណ្តោះអាសន្ននៅពន្ធនាគារខេត្តកោះកុង។ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៥ សាលាដំបូងខេត្តបានបដិសេធសំណើសុំនៅក្រៅឃុំ ដែលក្នុងពេលនោះក៏មានការតវ៉ាប្រឆាំងនឹងការបន្តឃុំឃាំងពួកគេដែរ។ [49] មកដល់ពេលនេះពួកគេបានស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល ១០ ខែមកហើយ។

៦៦. ការដាក់ឲ្យស្ថិតក្រោមការឃុំខ្លួនបណ្តោះអាសន្នក្នុងស្ថានភាពដែលមិនមានភស្តុតាងបញ្ជាក់ថាជនជាប់ឃុំទាំងបីពិតជាបានធ្វើការគំរាមកំហែងនោះ ស្តែងឱ្យឃើញពីការដកហូតសេរីភាពរបស់ពួកគេតាមអំពើចិត្ត។ ការឃុំខ្លួនត្រូវធ្វើឡើងសម្រាប់តែជាមធ្យោបាយចុងក្រោយបង្អស់ដោយអាស្រ័យលើភាពចាំបាច់ប៉ុណ្ណោះ។ ជាការពិត គ្មានមូលដ្ឋានណាមួយចែងពីការដាក់ពន្ធនាគារនៅមុនការជំនុំជម្រះក្នុងក្រមនីតិវិធីព្រហ្មទណ្ឌឡើយក្រៅតែពីដើម្បី ៖ [50]

ក. *បង្ការបទល្មើសកុំឱ្យកើតឡើងជាថ្មី* ៖ ស្ថិតនៅក្រោមការត្រួតពិនិត្យយ៉ាងតឹងរ៉ឹងពីសំណាក់អាជ្ញាធរ និងជាអ្នកដែលគេស្គាល់យ៉ាងច្បាស់នៅក្នុងសហគន៍ដោយសារសកម្មនិយមរបស់ពួកគេ ដូច្នេះពុំសមស្របឡើយដែលថា ជនជាប់ឃុំចូលរួមក្នុងសកម្មភាពខុសច្បាប់ណាមួយនោះ។ លើសពីនេះទៅទៀត ក្នុងករណីមានការបារម្ភថាជនជាប់ឃុំនឹងប្រព្រឹត្តបទល្មើសជាថ្មីម្តងទៀតនោះគួរតែមានការកំណត់លក្ខខណ្ឌសមរម្យណាមួយ ដើម្បីដោះលែងឱ្យនៅក្រៅឃុំ និងស្ថិតនៅក្រោមការឃ្លាំមើលរបស់តុលាការវិញ ។

---

[49] អូន ភាព "តុលាការបដិសេធសំណើសុំនៅក្រៅឃុំរបស់សកម្មជន ស្របពេលដែលអ្នកតវ៉ាធ្វើដំណើរទៅកោះកុង" ខេមបូឌា ដេលី ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥។ អាចរកបានតាមរយៈ ៖http://bit.ly/1KZ2AuC

[50] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ខ. *ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ* ៖ មិនមានភស្តុតាងបង្ហាញថាសកម្មជនដែលជាប់ឃុំអាចយាយីដល់សាក្សី ឬក៏ជនរងគ្រោះទេ។ បើពិចារណាទៅលើឥទ្ធិពលខុសគ្នារវាងសកម្មជន និងក្រុមហ៊ុនវិញ ការយាយីនេះមិនទំនងនឹងកើតឡើងទាល់តែសោះ។ ចំណែកសាក្សីវិញក៏ដូច្នោះដែរ សុទ្ធតែកាន់មុខតំណែងដែលមានឥទ្ធិពលនៅក្នុងនយោបាយ និងរដ្ឋបាល។

គ. *ដើម្បីរក្សាភស្តុតាង* ៖ មិនមានភស្តុតាងជាសម្ភារៈ ក្រៅតែពីសេចក្តីថ្លែងរបស់សាក្សីដែលលើកឡើងពីបទល្មើស។

ឃ. *ដើម្បីធានាវត្តមានជនត្រូវចោទ* ៖ ដោយសារជនជាប់ឃុំពីរនាក់បានចេញសារភាពឱ្យសមត្ថកិច្ចចាប់ខ្លួន ដូច្នេះការរត់គេចខ្លួនមានកម្រិតតិចតួចបំផុត។ លើសពីនេះទៅទៀត អ្នកទាំងបីងាយនឹងត្រូវរឹតត្បិតក្នុងការធ្វើដំណើរបើទោះជាពួកគេនៅក្រៅឃុំក៏ដោយ ។

ង. *ដើម្បីការពារសន្តិសុខជនត្រូវចោទ* ៖ នេះហាក់បីដូចជាមានហានិភ័យតិចតួចក្នុងអង្គហេតុនិងបរិបទជុំវិញករណីនេះ ដែលបង្ហាញថាជនជាប់ឃុំអាចទទួលរងគ្រោះថ្នាក់ក្នុងអំឡុងពេលដំណើរការសវនាការ។ គ្មានភស្តុតាងនៃហានិភ័យណាមួយត្រូវបានបង្ហាញនៅចំពោះមុខចៅក្រមស៊ើបអង្កេតឡើយ។

ច. *ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ* ៖ គ្មានភស្តុតាងណាដែលថាការដោះលែងជនជាប់ឃុំទាំងបីនាក់នោះនឹងអាចរំខានដល់សណ្តាប់ធ្នាប់សាធារណៈឡើយ។ មូលដ្ឋាននេះមិនអាចយកមកអនុវត្តដើម្បីឃុំខ្លួនអ្នកទាំងបីនាក់បានឡើយ ព្រោះបទពិសោធនៅក្នុងប្រទេសកម្ពុជានាពេលកន្លងមកបានបង្ហាញថាវាជាហេតុផលដើម្បីដាក់ពន្ធនាគារដល់សកម្មជនបរិស្ថាននិងសកម្មជនសហគមន៍ជាជាងការទប់ស្កាត់អសណ្តាប់ធ្នាប់សាធារណៈ។

៦៧. ផ្អែកលើការវិភាគទៅលើបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ បង្ហាញយ៉ាងច្បាស់ថាពុំមានហេតុផលសមរម្យក្នុងការឃុំខ្លួនបណ្តោះអាសន្នលើសចិរវេលោកំណត់លើរូបលោក សាន់ ម៉ាឡា លោកទ្រី សុវិកា និងលោកស៊ឹម សំណាង ឡើយ។ ខណៈពេលដែលតុលាការមានសមត្ថកិច្ចក្នុងការបញ្ជូនជនសង្ស័យទៅមន្ទីរឃុំឃាំងមុនសវនាការ ករណីនេះគួរត្រូវបានអនុវត្តតែក្នុងកាលៈទេសៈលើកលែងប៉ុណ្ណោះ។ ពុំមានលក្ខខណ្ឌពាក់ព័ន្ធណាមួយអាចអនុវត្តក្នុងករណីនេះឡើយ ។

៦៨. ទន្ទឹមនឹងការបំពានច្បាប់ជាតិ ការបន្តឃុំខ្លួនជនជាប់ឃុំទាំងបីនាក់បណ្តោះអាសន្នក៏រំលោភដល់ស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដែលអនុវត្តដោយផ្ទាល់នៅក្នុងច្បាប់កម្ពុជាផងដែរ។[51] ដូចបានបកស្រាយខាងលើ ការឃុំខ្លួនបណ្តោះអាសន្នដោយខ្វះនូវមូលដ្ឋានច្បាប់ត្រឹមត្រូវ និងអាចចាត់ទុកថាជាការធ្វើឡើងតាមតែអំពើចិត្ត និងខុសច្បាប់[52] ដែលហាមឃាត់ដោយមាត្រា ៩ នៃ ក.អ.ស.ព.ន ។

---

[51] ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចលេខ ០៩២/០០៣/២០០៧ (១០ កក្កដា ២០០៧)។

[52] សេចក្តីពន្យល់ទូទៅរបស់អង្គការសហប្រជាជាតិលេខ ៣៥ CCPR/C/GC/៣៥ (ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៤) [១១]។

៦៩. ទោះក្នុងករណីនេះ ប្រសិនបើការឃុំខ្លួនបណ្ដោះអាសន្នត្រូវបានចាត់ទុកថាសមហេតុផលតាមផ្លូវច្បាប់នោះ ក៏ថិរវេលាដែលជនត្រូវចោទទាំងនោះជាប់ឃុំដោយមិនត្រូវបានគេនាំយកទៅជំនុំជម្រះនោះ នឹងចាត់ថាជាការរំលោភទៅលើមាត្រា៩ (៣) និងមាត្រា ១៤ (៣)(ឃ) នៃ ក.អ.ស.ព.ន ដែលចែងថា ជនជាប់ឃុំពីការចោទប្រកាន់ព្រហ្មទណ្ឌមានសិទ្ធិទទួលបានការជំនុំជម្រះក្នុងរយៈពេលសមរម្យ និងដោយពុំពន្យារពេល។ ដូច្នេះ នេះគឺជាការឃុំខ្លួនពួកគេរយៈពេលយូរតាមតែអំពើចិត្តដែលជាការរំលោភបំពានបន្ថែមទៀតទៅលើសិទ្ធិមនុស្សរបស់គេដែលត្រូវបានធានាជាលក្ខណៈអន្តរជាតិ។

***សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌***

៧០. លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស សព្វថ្ងៃត្រូវបាននិរទេសខ្លួនទាំងបង្ខំចេញពីប្រទេសកម្ពុជា ដែលការបណ្ដេញចេញនេះត្រូវបានរាយការណ៍ថាជាការរៀបចំឡើងតាមបញ្ជារបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីខែកុម្ភៈ ឆ្នាំ២០១៥ ។[53] ការបណ្ដេញលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ចេញពីប្រទេសកម្ពុជាត្រូវបានគេជឿថាមានជាប់ពាក់ព័ន្ធដោយផ្ទាល់ទៅនឹងជំហរសកម្មនិយមបរិស្ថានប្រឆាំងនឹងការសាងសង់ទំនប់វារីអគ្គិសនីឆាយអារ៉ែងដែលស្ថិតនៅក្នុងខេត្តកោះកុង។

៧១. ចាប់តាំងពីត្រូវបានចោទប្រកាន់នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បានទាមទារឱ្យមានការគោរពសិទ្ធិការពារខ្លួនដោយផ្ទាល់[54] ដែលបានធានាតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា ១៤ នៃ ក.អ.ស.ព.ន ។ លក្ខខណ្ឌសម្រាប់ជនត្រូវចោទក្នុងការចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ គឺត្រូវបានតម្រូវបន្ថែមតាមមាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មាត្រា ៣៦១ និង មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌគូសបញ្ជាក់យ៉ាងច្បាស់ថា សវនាការកំបាំងមុខគួរធ្វើឡើងតែក្នុងករណីដែលជនត្រូវចោទមិនចូលបង្ហាញខ្លួន ឬបដិសេធបង្ហាញខ្លួននៅចំពោះមុខតុលាការប៉ុណ្ណោះ។ ផ្ទុយទៅវិញ លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស បានបញ្ជាក់ម្ដងហើយម្ដងទៀតពីចេតនារបស់ខ្លួនដើម្បីបានចូលតតាំងក្នុងសវនាការនៅកម្ពុជាដែលស្របទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ លោកត្រូវបានបន្តរាំងក្នុងការត្រឡប់មកកម្ពុជាវិញ បើទោះបីជាមានដីកាកោះ និងដីកាចាប់ខ្លួនប្រឆាំងរូបលោកក៏ដោយ។

៧២. ក្រុមអង្គការសង្គមស៊ីវិលកម្ពុជាបានគាំទ្រការទាមទារសិទ្ធិមានវត្តមានក្នុងពេលសវនាការរបស់លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដោយមានអង្គការមិនមែនរដ្ឋាភិបាលចំនួន ២២ អំពាវនាវឱ្យមានការគោរពសិទ្ធិរបស់លោកដើម្បីទទួលបានការជំនុំជម្រះដោយយុត្តិធម៌កាលពីថ្ងៃទី១៤ ខែកុម្ភៈ

[53] គាត ឧត្តម ម៉ៃ ទិត្យថារ៉ា ដាញែល ភិយ (Daniel Pye) និងគ្រីហ្វ ថេភើ (Griff Tapper)"សកម្មជនដែលរឹងទទឹងត្រូវបានបណ្ដេញចេញ" *ភ្នំពេញប៉ុស្តិ៍* ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥។ អាចរកបានតាមរយៈ ៖ http://bit.ly/1Rh7gUF

[54] អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដាវីដសុន (លិខិតអ្នកអាន) ៖ "វាដល់ពេលសម្រាប់ខ្ញុំត្រូវត្រឡប់ទៅវិញ" ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៦ ។

ឆ្នាំ២០១៦។[55] ទោះបីជាមានសំណើទាំងនេះក្តី នៅថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ រដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានលុបចោលទិដ្ឋាការដែលបានផ្តល់ឱ្យ អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដែលលោកបានដាក់ពាក្យស្នើសុំតាមរយៈប្រព័ន្ធអ៊ីធឺណិត ហើយអះអាងថាការដែលផ្តល់ឱ្យនោះគឺដោយសារតែ "*កំហុសបច្ចេកទេស*" ដែលតាមការពិតឈ្មោះគាត់ត្រូវបានគេបញ្ចូលទៅក្នុងបញ្ជីខ្មៅរួចហើយ។ [56] យោងតាមមាត្រា ៥២០ នៃក្រមព្រហ្មទណ្ឌ "បទបដិសេធការអនុវត្តសេចក្តីសម្រេចរបស់តុលាការ" អ្នករាជការសាធារណៈដែលមិនគោរពបញ្ជារបស់តុលាការ ដូចជាដីកាបង្គាប់ឱ្យចាប់ខ្លួន ឬដីកាកោះ គឺជាការប្រព្រឹត្តបទល្មើស ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ឆ្នាំទៅ៤ ឆ្នាំ។ ដើម្បីអនុវត្តតាមបទបញ្ញត្តិចំពោះករណីនេះ មន្ត្រីអន្តោប្រវេសន៍កម្ពុជាមានកាតព្វកិច្ចអនុញ្ញាតឲ្យគាត់ចូលមកក្នុងប្រទេសកម្ពុជាដើម្បីឱ្យគាត់មកអនុវត្តតាមការទទួលយកដីកាកោះ និងដីកាចាប់ខ្លួនដោយផ្ទាល់ ។

៧៣. សិទ្ធិមានវត្តមានក្នុងពេលសវនាការ គឺជាធាតុផ្សំសំខាន់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចបានការពារតាមមាត្រា ១៤ (៣) (ឃ) នៃ ក.អ.ស.ព.ន និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ ខណៈដែលកម្ពុជាមានបទប្បញ្ញត្តិស្តីពីសវនាការកំបាំងមុខ បញ្ញត្តិនេះអាចអនុវត្តបានតែក្នុងករណីដែលជនជាប់ចោទមិនអាចត្រូវបាននាំខ្លួនទៅកាន់អង្គជំនុំជម្រះ ដោយសារអសមត្ថភាពរបស់អាជ្ញាធរពាក់ព័ន្ធដើម្បីនាំខ្លួន/ចាប់ខ្លួនដូចមានចែងក្នុងមាត្រា ៣៦១ និង មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌប៉ុណ្ណោះ។

## ៧ សេចក្តីសន្និដ្ឋាន

៧៤. ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រការចោទប្រកាន់ទៅលើជនត្រូវចោទទាំងបួននាក់នៅក្នុងករណីនេះឡើយ ផ្ទុយទៅវិញវាជាការព្យាយាមផ្តល់សក្ខីកម្មដាក់បន្ទុកដូចមានបញ្ញត្តិនៅក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ។ ក្នុងរឿងក្តីជនជាប់ឃុំទាំងបីនាក់នេះ ពុំមានភស្តុតាងពិតប្រាកដដែលគាំទ្រដល់ការចោទប្រកាន់ដែលអាចបង្ហាញថាពួកគេបានគំរាមកំហែងបំផ្លិចបំផ្លាញ ឬធ្វើឱ្យខូចខាតទ្រព្យសម្បត្តិក្រៅតែពីការលើកឡើងនូវក្រុមមនុស្សមិនមានអត្តសញ្ញាណក្នុងចំណោមមនុស្សជាច្រើននាក់។ ផ្ទុយទៅវិញ ភស្តុតាងនោះបានបង្ហាញពីអាកប្បកិរិយាអហិង្សាទាំងស្រុងរបស់ពួកគេនិងសកម្មភាពផ្សព្វផ្សាយពីគោលការណ៍អហិង្សាដល់សមាជិកសហគមន៍ដែលប្រមូលផ្តុំ ដែលអនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ បង្ហាញថាការដាក់បន្ទុកមិនសមស្របតាមលក្ខខណ្ឌតម្រូវនិងការសន្មតទុកជាមុនថាគ្មានទោសដែលតម្រូវឱ្យមានការលើកលែងការចោទប្រកាន់ទៅលើជនត្រូវចោទទាំងបួននាក់នោះ ។

---

[55] សេចក្តីថ្លែងការណ៍រួម ៖ "អង្គការសង្គមស៊ីវិលប្រកាសគាំទ្រអង្គការមាតាធម្មជាតិ និងថ្កោលទោសចំពោះការបង្ក្រាបលើអង្គការនេះ" ភ្នំពេញ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៦។ អាចរកបានតាមរយៈ ៖ http://bit.ly/1RYPD6U

[56] អូន ភាព និង អាឡិច វីលែមិនស៍ (Alex willemyns) "ក្រសួងមហាផ្ទៃលុបចោលទិដ្ឋការសម្រាប់សកម្មជនជនជាតិអេស្ប៉ាញដែលត្រូវបានបណ្តេញចេញ" ខេមបូឌា ដេលី ថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៥ ។

៧៥. លើសពីនេះ ដោយមិនគិតពីអង្គសេចក្តីនៃការចោទប្រកាន់បច្ចុប្បន្ននេះ ការ ឃុំខ្លួនបណ្តោះអាសន្ន ក្នុងរយៈពេលយូរទៅលើ ទ្រី សុរិគា សាន់ ម៉ាឡា និង ស៊ឹម សំណាង ត្រូវបានគេមើលឃើញថាធ្វើឡើង តាមអំពើចិត្ត និងខុសច្បាប់ ជាការរំលោភដល់សិទ្ធិមានសេរីភាព និងការជំនុំជម្រះដោយយុត្តិធម៌ តាម មាត្រា ៩ និងមាត្រា ១៤ នៃ ក.អ.ស.ព.ន និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ស្របពេលដែលមាន ការខកខានក្នុងការបំពេញតាមលក្ខខណ្ឌចាំបាច់នៃបទដ្ឋានសម្រាប់ការឃុំខ្លួនបណ្តោះអាសន្នដែល មានចែងនៅមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៧៦. ការចោទប្រកាន់លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ថាជាអ្នកសមគំនិត ហាក់រកមិនឃើញនូវ ភស្តុតាងដែលគួរឱ្យជឿទុកចិត្ត និងមិនសមស្របតាមច្បាប់។ គ្មានសកម្មភាពជាក់លាក់ណាមួយ ប្រព្រឹត្តដោយលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ដែលអាចធ្វើជាមូលដ្ឋានសម្រាប់ការចោទ ប្រកាន់ឡើយ ហើយក៏គ្មានភស្តុតាងណាបង្ហាញថាគាត់ដឹងជាមុន ឬផ្តល់ជំនួយដល់ជនជាប់ឃុំឱ្យ ប្រព្រឹត្តបទល្មើសនោះដែរ។ ម្យ៉ាងវិញទៀត កង្វះភស្តុតាងក្នុងការចោទប្រកាន់លើជនជាប់ឃុំទំនងជា មិនអាចគាំទ្រដល់ការចោទប្រកាន់លោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ជាវីដេសុន ពីបទសមគំនិត បានឡើយ។ ការនិរទេសលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស ទាំងបង្ខំចេញពីប្រទេសកម្ពុជា គឺជា ការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌និងសិទ្ធិមានវត្តមាននៅពេលសវនាការផងដែរ។ ពុំមានហេតុផលត្រឹមត្រូវតាមផ្លូវច្បាប់ចំពោះសវនាការកំបាំងមុខនៅក្នុងករណីនេះទេ។ ការជំនុំជម្រះ ដោយកំបាំងមុខនៅក្នុងកាលៈទេសៈនេះអាចជាការបំពានលើមាត្រា ១៤ នៃ ក.អ.ស.ព.ន ព្រមទាំង មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងមិនស្របតាមមាត្រា ៣៦១ និងមាត្រា ៣៦២ នៃក្រមនីតិវិធី ព្រហ្មទណ្ឌ។

៧៧. ផ្អែកតាមការវិភាគទៅលើការចោទប្រកាន់ ភស្តុតាង និងច្បាប់ដែលអនុវត្ត អាចសន្និដ្ឋានបានថា ប្រសិនបើជនជាប់ឃុំទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងឯករាជ្យ នោះពួកគេច្បាស់ជារួចផុតពី បទចោទប្រកាន់ទាំងអស់ និងត្រូវបានដោះលែងឱ្យមានសេរីភាព ហើយការចោទប្រកាន់ទៅលើលោក អាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស នឹងត្រូវទម្លាក់ចោលដោយសារមិនមានសកម្មភាពប្រព្រឹត្តបទល្មើស។ តែប្រសិនបើអាឡិចហ្សង់ដ្រូ ហ្គុនហ្សាឡេហ្ស នឹងត្រូវទទួលការជំនុំជម្រះនោះលោកត្រូវតែទទួលបាន ការអនុញ្ញាតឱ្យចូលក្នុងប្រទេសកម្ពុជា ព្រោះសិទ្ធិមូលដ្ឋានរបស់លោកត្រូវបានធានាឱ្យមានវត្តមានក្នុង ពេលសវនាការ ហើយប្រសិនបើការជំនុំជម្រះនោះយុត្តិធម៌ និងឯករាជ្យ នោះបទចោទទៅលើរូបលោក ទាំងអស់ក៏នឹងត្រូវទម្លាក់ចោលផងដែរ។

៧៨. ជាងនេះទៅទៀតនោះ ការចោទប្រកាន់ដែលគ្មានមូលដ្ឋានផ្លូវច្បាប់ទៅលើបុគ្គលទាំងបួនរូប និង ការឃុំខ្លួនទាំងបីរូបក្នុងចំណោមពួកគេដោយសារតែសកម្មភាពតវ៉ាសន្តិវិធីបង្ហាញយ៉ាងច្បាស់ពីការ រំលោភទៅលើសិទ្ធិសេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការប្រមូលផ្តុំរបស់ពួកគេ។ ការចោទ ប្រកាន់ពួកគេដោយផ្អែកលើភស្តុងតាងទន់ខ្សោយដូចបានគូសបញ្ជាក់ខាងលើ នឹងនាំឱ្យមានការ

រំលោភបំពានធ្ងន់ធ្ងរបន្ថែមទៀតទៅលើសិទ្ធិទាំងនោះ និងជាការបំភិតបំភ័យធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តការងាររបស់ពួកគេក្នុងប្រទេសកម្ពុជានាពេលអនាគត។

# *ឧបសម្ព័ន្ធទី ១ ៖ ការឆ្លើយឆ្លងតាមទំព័រហ្វេសប៊ុក (រូបភាពលើអេក្រង់)*




*រូបភាពទី ១ ៖ ទ្រី សុវិកា បញ្ជាក់ថាលោកកំពុងធ្វើដំណើរទៅ ដង ទុង (ជាឈ្មោះតំបន់មួយ ក្នុងខេត្តកោះកុង) នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥*




*រូបភាពទី ២ ៖ សារបង្ហាញថា ស៊ីម សំណាង បានចាកចេញពីតំបន់អណ្តូងទឹក មុនពេលការតវ៉ាបានចាប់ផ្តើមនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥*

# ឧបសម្ព័ន្ធទី ១ (ត)




*រូបភាពទី៣ ៖ អាឡិចហ្សង់ដ្រូ ហ្គនហ្សាឡេហ្ស ដាវីដសុន ផ្ញើសារទៅកាន់សកម្មជន និងបានគូសបញ្ជាក់ពីសារៈសំខាន់នៃអហិង្សា*




*រូបភាពទី ៤ ៖ អាឡិចហ្សង់ដ្រូ ហ្គនហ្សាឡេហ្ស ដាវីដសុន កំពុងទាក់ទងជាមួយ ស៊ីម សំណាង អំពីអហិង្សា។*

## *ឧបសម្ព័ន្ធទី២ ៖ វីដេអូដែលថតដោយ សាន់ ម៉ាឡា នៅថ្ងៃទី១២ ខែសីហា*

វីដេអូនេះនឹងមានផ្តល់ជូន បើមានការស្នើសុំ ហើយអាចរកបាននៅក្នុងគេហទំព័រយូធូបរបស់អង្គការមាតាធម្មជាតិនៅទីនេះ។

**ការស្រង់សម្តីពីវីដេអូ ៖**

*បាទជម្រាបសួរពុកម៉ែបងប្អូនទាំងអស់គ្នាជាទីមេត្រី! បាទ នៅថ្ងៃនេះ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ នេះប្រជាពលរដ្ឋនៅក្នុងស្រុកបទុមសាគរ នៅក្នុងឃុំអណ្តូងទឹក បានលើកគ្នាមកបណ្តេញក្រុមហ៊ុនដែលធ្វើការបូមខ្សាច់នៅស្រុកបទុមសាគរនេះសាជាថ្មី ដោយសារវាបានចូលមកបូមទៀតហើយអត់បានគោរពនូវកិច្ចសន្យាដែលយើងបានព្រមព្រៀងគ្នាថាលុះត្រាតែមានក្រុមអធិការកិច្ចចុះមកវាយតម្លៃសាជាថ្មីបានគេអាចធ្វើអាជីវកម្មឬធ្វើសកម្មភាពបន្តទៀតបាន។ ឥឡូវនេះខាងក្រុមហ៊ុនគេបានរៀបចំយុទ្ធសាស្រ្តថ្មី តាមពិតទៅយុទ្ធសាស្រ្តដដែលៗគេធ្លាប់បានប្រើគ្រប់កន្លែងហើយគឺគេជួលប្រជាជនមួយចំនួនដែលរស់នៅក្នុងឃុំអណ្តូងទឹក ស្រុកបទុមសាគរហ្នឹងចំនួនជាងដប់នាក់ដើម្បីយកមកការពារក្រុមហ៊ុនហើយទុកបង្កអំពើហិង្សា និងការប្រឈមមុខដាក់គ្នារវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ ប៉ុន្តែសកម្មជនយើងព្យាយាមធ្វើយ៉ាងណាដើម្បីបញ្ចៀសអំពើហិង្សា និងរក្សាភាពស្ងៀមស្ងាត់ ហើយយើងក៏នៅតែបន្តឆន្ទៈក្នុងការបណ្តេញក្រុមហ៊ុននេះឲ្យត្រឡប់ទៅវិញដែរ។ សូមទស្សនារូបភាពប្រជាពលរដ្ឋទាំងអស់គ្នា។ សូមពុកម៉ែបងប្អូនទាំងអស់គ្នាជួយចែករំលែកវីដេអូមួយនេះផង។ បាទ សូមអរគុណច្រើន។*

## *ឧបសម្ព័ន្ធទី៣ ៖ វីដេអូជាសារសំឡេងពី ទ្រី សុវិគា នៅថ្ងៃទី១២ ខែសីហា*

វីដេអូនេះនឹងមានផ្តល់ជូន បើមានការស្នើសុំ ហើយអាចរកបាននៅក្នុងគេហទំព័រយូធូបរបស់អង្គការមាតាធម្មជាតិនៅទីនេះ។

**ការស្រង់សម្តីពីវីដេអូ ៖**

*(សាន់) ម៉ាឡា គាត់បានខល (ទូរសព្ទ) ប្រាប់ខ្ញុំថាឥឡូវហ្នឹងមានខាងប្រជាជនខាងភូមិឥស្លាមដប់នាក់ ដែលគេជួលធ្វើជាកម្មករសោឡង់ហ្នឹងកំពុងរារាំងពួកយើង (អ្នកតវ៉ា) អត់ឲ្យឡើងលើកញ្ជាប់ (ម៉ាស៊ីនបូមខ្សាច់) ហ្នឹងទេ។ ប៉ុន្តែពួកយើង (សកម្មជន) ពួកយើងឡើងហើយហើយ (រួចហើយ) ហើយកំពុងទប់ស្កាត់កុំឱ្យមានអំពើហិង្សាកើតឡើង។*